១៨. ហើយទៅចំពោះមេឃ ដូចម្តេចទៅដែលគេកសាងឡើង ។	وَإِلَى السَّمَاءِ كَيْفَ رُفِعَتْ 18
១៩. ហើយទៅចំពោះបណ្តាភ្នំដ៏ៗ ដូចម្តេចទៅដែលគេបានដោតភ្ជាប់ទៅនឹងដីយ៉ាងមាំ។	وَإِلَى الْجِبَالِ كَيْفَ نُصِبَتْ 19
២០. ហើយទៅចំពោះផែនដី ដូចម្តេចទៅដែលគេលាតក្រាលវានោះ ។	وَإِلَى الْأَرْضِ كَيْفَ سُطِحَتْ 20
២១. ដើម្បីបាន ចូរអ្នកឯងរំឭកលោកចុះ ពិតប្រាកដ ឯងជាអ្នករំឭក	فَذَكِّرْ إِنَّمَا أَنتَ مُذَكِّرٌ 21
២២ អ្នកឯងគ្មានអំណាចត្រួតត្រា ទៅលើអ្នកទាំងអស់នោះទេ ។	لَسْتَ عَلَيْهِم بِمُصَيْطِرٍ 22
២៣ ក៏ប៉ុន្តែ អ្នកណាដែលបែរខ្នង(រំលោភរំលង) ហើយគ្មានជំនឿ	إِلَّا مَن تَوَلَّىٰ وَكَفَرَ 23
២៤ ដើម្បីបាន អល់ឡោះនឹងធ្វើទារុណកម្មវា នោះ ទារុណកម្ម ដ៏យ៉ាងធ្ងន់ធ្ងរបំផុត	فَيُعَذِّبُهُ اللَّهُ الْعَذَابَ الْأَكْبَرَ 24

២៥. ពិតប្រាកដ ចំពោះយើងហើយ អ្នកទាំងអស់នោះ ត្រូវវិលត្រឡប់ ។ إن إلينا إيابهم ٢٥

២៦. បន្ទាប់មកពិតប្រាកដ លើយើងហើយ ដែលជាអ្នកកាត់ទោស ជំនុំជំរះ អ្នកទាំងអស់នោះ ។ ثم إن علينا حسابهم ٢٦

បិទកាថាវគ្គ វគ្គនេះ បានជម្រុលបង្ហាញ អំពីដំណើរការណ៍ និងយល់ឃើញ អំពីបណ្ដាអ្នកដែលគ្មានជំនឿ ហើយនិងបង្ហាញ អំពី ផលតបស្នងនៃសេចក្ដីសុខ ទុក្ខវេទនា របស់បណ្ដាអ្នកដែលមានជំនឿក្ដី នៅថ្ងៃបរលោក ។

ម្ចាស់ដ៏មហាខ្ពង់ខ្ពស់ الأعلى

កំណើតវគ្គ វគ្គនេះគេបានបញ្ចុះនៅម៉ាក្កាស់ ដែលមាន ១៩ ឃ្លា ។

គេបានបញ្ចុះវគ្គនេះ ក្រោយពីពេលដែលគេបានបញ្ចុះវគ្គ التكوير ឈ្មោះ الأعلى មានន័យថា ម្ចាស់ដ៏មហាខ្ពង់ខ្ពស់

ដោយគេយកសព្ទពាក្យសំដី الأعلى ដែលមាននៅក្នុងឃ្លាទីមួយបង្អស់ នៃវគ្គនេះ ។

សហិហ៍ មូស្លិម បាននិទានឡើងក្នុងគីតាប الجمعة

គេនិទានថា អ្នកដែលស្គាល់តាមផ្លូវរបស់ សាវ: (ណាប៊ី) សូលុលឡូហ៊ូអាឡៃហ៊ីវ៉ាសាល្លាំ សំពីអ្នកមិនអ្នកញាស្សៀវ គាត់មានប្រសាសន៍ថា ក្នុងការគោរពសំពះថ្វាយបង្គំ (صلاة) នៅថ្ងៃបុណ្យទាំងពីរ (الفطر និង الأضحى) និងថ្ងៃ យមអាត់នោះឯង រ៉ស៊ូលុលឡោះ បានសូត្រ វគ្គ الأعلى នៅក្នុង រ៉ាកាត់ទី១ ហើយសូត្រវគ្គ الغاشية នៅក្នុង រ៉ាកាត់ទី២ ។

គោលការណ៍សំខាន់ៗក្នុងន័យរបស់វគ្គ

- បញ្ជារបស់ អល់ឡោះ អោយសូត្រសរសើរ និងរំឭកព្រះនាមរបស់ទ្រង់ ។
- សាវ:(ណាប៊ី) មូហាំម៉ាត់ សូលុលឡូលឡូហ៊ូអាឡៃហ៊ីវ៉ាសាល្លាំ ទ្រង់ដកស្រង់ឃ្លា ទៀតយកខ្លះ ឃ្លាណានៃគូរអាន ដែលគេបានសូត្រ នៅចំពោះគាត់ ។
- ផលប្រយោជន៍ដែលនាំអោយ មនុស្សលោក បានទទួល លាភសំណាងស្ដុះស្ដើង នៅក្នុងលោក និង ឋានបរលោក ។
- អល់ឡោះ បានបង្កើត ហើយបានបំពេញគ្រប់លក្ខណៈ ក្នុងការបង្កើតរបស់ ទ្រង់ ហើយនាំផ្លូវ ការនឹកឭឯកតារបស់ទ្រង់ ។
- ហើយបានបង្ហាញ ទៀតបានបំពេញការចាំបាច់របស់មនុស្សលោក លុះត្រាតែបានដល់នូវពេលបំណាច់របស់វា (មនុស្សលោក) ។ ។

الاعلى

ម្ចាស់ដ៏មហាខ្ពង់ខ្ពស់

ដោយព្រះនាមអល់ឡោះ ម្ចាស់ទ្រង់មហា
ករុណាណាស់ ទៀតទ្រង់មហា មេត្តាប្រណី ។

بِسْمِ اللَّهِ الرَّحْمَٰنِ الرَّحِيمِ

១ សំអាតព្រះនាមម្ចាស់របស់ឯងដ៏មហា
ខ្ពង់ខ្ពស់ ។

١ سَبِّحِ اسْمَ رَبِّكَ الْأَعْلَى

២ ទ្រង់បានបង្កើត ហើយទ្រង់បានបំពេញ
រូបលក្ខណ: (នៃអស់សត្វលោក)

٢ الَّذِي خَلَقَ فَسَوَّىٰ

៣ ហើយទ្រង់ជាអ្នកដែលបានកាត់កំរិត ហើយ
នឹងបានចង្អុលបង្ហាញ ។

٣ وَالَّذِي قَدَّرَ فَهَدَىٰ

៤ ហើយទៀតទ្រង់ជាអ្នកបណ្ដុះរុក្ខជាតិ ។

٤ وَالَّذِي أَخْرَجَ الْمَرْعَىٰ

៥ ហើយទ្រង់បានធ្វើអោយរុក្ខជាតិនោះ
ក្លាយទៅជា ស្មៅស្ងួត ។

٥ فَجَعَلَهُ غُثَاءً أَحْوَىٰ

៦ យើងនឹងសូត្រសំរាប់ឯង ចំពោះឯង ដើម្បី
បានជា កុំអោយឯងភ្លេច ។

٦ سَنُقْرِئُكَ فَلَا تَنْسَىٰ

៧ លើកលែងតែ ប្រើជាអល់ឡោះ បានសព្វព្រះ-
ហឫទ័យ ទ្រង់ជ្រាបនូវការអាថ៌កំបាំង ហើយនឹងទៀត

٧ إِلَّا مَا شَاءَ اللَّهُ إِنَّهُ يَعْلَمُ
الْجَهْرَ وَمَا يَخْفَىٰ

ដែលលាក់ពីកំបាំង ។

៨. ហើយយើងនឹងសម្រួលអោយឯងទៅ
ចំពោះផ្លូវដែលងាយស្រួល ។

٨ وَنُيَسِّرُكَ لِلْيُسْرَىٰ

៩. ដូច្នេះ ចូរឯងរំឭកចុះ ពិតប្រាកដ
ការរំឭកនោះនឹង មានផលប្រយោជន៍ណាស់ ។

٩ فَذَكِّرْ إِن نَّفَعَتِ الذِّكْرَىٰ

១០. គង់តែភ្ញាក់រឭកដែរ អ្នកដែលមានលក្ខណៈកោត
ខ្លាចនោះ ។

١٠ سَيَذَّكَّرُ مَن يَخْشَىٰ

១១. ហើយនឹងជៀសវាងវាពីវា(ការរំឭក) អ្នកដែល
ទុច្ចរិតនោះ ។

١١ وَيَتَجَنَّبُهَا الْأَشْقَى

១២. អ្នកនោះហើយ នឹងចូលក្នុងរងរនរកដ៏ធំធេង

١٢ الَّذِي يَصْلَى النَّارَ الْكُبْرَىٰ

១៣. បន្ទាប់មកទៀតនោះ គ្មានស្លាប់ទេ ហើយគ្មានរស់
ទេ ទៀតផង (ខាងនរក)

١٣ ثُمَّ لَا يَمُوتُ فِيهَا وَلَا يَحْيَىٰ

១៤ ពិតប្រាកដ បានជោគជ័យហើយ អ្នកដែល
បានសំអាត (កាយនិងចិត្តពីការប្រឆាំងនិងការ
ទុច្ចរិត)

١٤ قَدْ أَفْلَحَ مَن تَزَكَّىٰ

១៥. ហើយបានរំឭកព្រះនាមម្ចាស់របស់វា ហើយ
ទៀតសោតបាន គោរពសមាធិបាយបង្គំ(صلى)
(ទៅចំពោះ ព្រះអល់ឡោះម្ចាស់របស់វា)

١٥ وَذَكَرَ اسْمَ رَبِّهِ فَصَلَّىٰ

១៦ ក៏ប៉ុន្តែ ពួកឯងទាំងអស់គ្នា ស្រឡាញ់ការរស់
នៅក្នុងលោកិយនេះ ។ — بَلْ تُؤْثِرُونَ الْحَيَوٰةَ الدُّنْيَا ١٦

១៧. ការពិត ថ្ងៃបរលោក នោះហើយ ដ៏ល្អ
មហាប្រសើរលើស ទៀតនិងជាអមតៈ ។ — وَالْآخِرَةُ خَيْرٌ وَأَبْقَىٰ ١٧

១៨. ពិតប្រាកដ រឿងទាំងអស់នេះមាននៅក្នុងបណ្ដាំ
គម្ពីរ ដែលពីមុនៗមក ។ — إِنَّ هَٰذَا لَفِي الصُّحُفِ الْأُولَىٰ ١٨

១៩. គឺគម្ពីរ របស់ អ៊ីប្រាហ៊ីម ហើយនិងមូសា ។ — صُحُفِ إِبْرَاهِيمَ وَمُوسَىٰ ١٩

ចំពោះជំពូក ៧ផ្ទុះនេះ បានបង្ហាញនៅយ៉ាងច្បាស់ ពីលក្ខណៈរបស់
អល់ឡោះ ហើយទៀតបានបញ្ជាក់ឲ្យ ឯកលក្ខណៈរបស់ សារៈ(ពាក្យ)
មូហាំម៉ាត់ ស៊ូលឡលឡហ៊ូអាឡៃហ៊ីវាសាល្លាំ ។
ហើយនិងបណ្ដាំ អ្នកនៃលទ្ធានិយមអំពីអ៊ីស្លាម ក្នុងពិភពលោក ក្នុងសញ្ញា-
-យ នៅថ្ងៃ បរលោក ។

ផ្កាយដែលមានពន្លឺនាពេលរាត្រី الطارق

កថាវគ្គ វគ្គនេះគេបានបញ្ចុះនៅម៉ាក្កាស់ ដែលមាន ១៧ បន្ទូល ។
គេបានបញ្ចុះវគ្គនេះ ក្រោយពីពេលដែលគេបានបញ្ចុះវគ្គ البلد
ឈ្មោះ الطارق មានន័យថា ផ្កាយដែលមានពន្លឺនាពេលរាត្រី
គេយកមករំលឹកពាក្យសំដី الطارق នៅក្នុងបន្ទូលដំបូងបង្អស់នៃវគ្គនេះ។

គោលការណ៍ដ៏សំខាន់ៗក្នុងន័យរបស់វគ្គ

អល់ឡោះបានថែ រក្សា ការពារ តាមរស់ វិញ្ញាណ ។

សញ្ញាំងគិតលោយបានដឹងឱលំងងំផុះ រំលឹកដើមកំណើតរបស់អ្នកឯង ។ អ្នកឯងនោះ គេបានបង្កើតអំពីដំណក់ទឹកកាម (منى) របស់ជាតិបុរសនិងស្ត្រី លាយច្របល់គ្នាដែកប្រណ្ណាពេ បើអ្នកឯងគិតឃើញដើមកំណើតរបស់អ្នកឯងដូចនេះហើយ ត្រូវតែដឹងថាអ្នកឯងនឹងបំបាត់នូវលក្ខណៈដែលផ្ញើឫកពាដ់ ហើយនិងអាកប្បកិរិយាក្អេងក្អាងនោះ ពេលចេញជាឯងតទៀត ។

អល់ឡោះមានឫទ្ធិអាចបង្កើតគេឲ្យរស់ឡើងវិញ នៅថ្ងៃបរលោក ។
នៅពេលនោះហើយ គ្មានអំណាចអ្វីឡើយ ក្រៅពីអល់ឡោះជាម្ចាស់នោះ និងមកជួយមនុស្សលោកនេះ បានឡើយ ។
អាល់គួរអាន (القرآن) ជាបន្ទូលដែលកាត់ញែករវាង យុត្តិធម៌ រវាងការពិតប្រាកដ ហើយនិងការលេងលោបះ។

الطارق

ផ្កាយដែលមានពន្លឺនាពេលរាត្រី

និងព្រះនាមអល់ឡោះម្ចាស់ប្រោសមហា بِسْمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ

សាវតារ៍ទៀតត្រូវមួយហៅថាបត្ត្រប្រណីត ។

១. (អល់ឡោះ) ទ្រង់ស្បថនឹងមេឃ ហើយនិងផ្កាយ ។ — ١ وَالسَّمَاءِ وَالطَّارِقِ

២. ហើយ តើអ្វីធ្វើឲ្យអ្នកដឹងថាផ្កាយនោះ ? — ٢ وَمَا أَدْرَاكَ مَا الطَّارِقُ

៣. គឺនោះ ផ្កាយមានពន្លឺចែងចាំងភ្លឺខ្លាំង — ٣ النَّجْمُ الثَّاقِبُ

៤. មិនមានទេ ខ្លួនរបស់នីមួយៗនោះ លើកលែងតែ មានលើវានោះមានអ្នកត្រួតត្រា — ٤ إِنْ كُلُّ نَفْسٍ لَمَّا عَلَيْهَا حَافِظٌ

៥. ចូរមនុស្សត្រិះរិះគិតមើល មនុស្សលោកកើតមកពីអ្វី — ٥ فَلْيَنْظُرِ الْإِنْسَانُ مِمَّ خُلِقَ

៦ គេបង្កើតវា ពីទឹកកាមដែលបាញ់ចេញ (ចេញពីប្រុសហើយនិងស្រី) — ٦ خُلِقَ مِنْ مَاءٍ دَافِقٍ

៧. គឺចេញពីរវាងឆ្អឹងខ្នងរបស់ប្រុស និងឆ្អឹងទ្រូងរបស់ស្រី ។ — ٧ يَخْرُجُ مِنْ بَيْنِ الصُّلْبِ وَالتَّرَائِبِ

៨. ពិតប្រាកដ (អល់ឡោះ) ទ្រង់ជាអ្នកមានអំណាច បង្កើតវាឡើងវិញ (ក្រោយពីស្លាប់) — ٨ إِنَّهُ عَلَىٰ رَجْعِهِ لَقَادِرٌ

៩ នៅថ្ងៃនោះ គេបានបញ្ចេញទាំងអស់ ការលាក់បាំងទុក ។

9 يَوْمَ تُبْلَى السَّرَائِرُ

១០ ហើយបានជា គ្មានទេ សំរាប់វា (មនុស្ស លោក) នូវកំលាំង ហើយគ្មានអ្នកណា ជួយទៀតនឹងជួយវា ។

10 فَمَا لَهُ مِنْ قُوَّةٍ وَلَا نَاصِرٍ

១១. (ព្រះអល្លោះ) បានស្បថ នឹងមេឃ ដែលមានទឹកភ្លៀង ដែលវិលត្រឡប់មក ដដែលនឹងវិញ ។

11 وَالسَّمَاءِ ذَاتِ الرَّجْعِ

១២. ហើយនឹងដីដែលមានប្រះឡើង ពោរពេញទៅដោយរុក្ខជាតិ ។

12 وَالْأَرْضِ ذَاتِ الصَّدْعِ

១៣ ពិតប្រាកដ ការលោកការ (القرآن) នោះ ប្រាកដជាមាន ព្រះបន្ទូល ដែលកាត់ ពាក្យសំដី (ការពិត ហើយនឹងការដែលបោះ) ។

13 إِنَّهُ لَقَوْلٌ فَصْلٌ

១៤. ហើយគ្មានទេ នៅក្នុងវា (គម្ពីរកុរអាន) ការដែលកំប្លែងលេងនឹង (ការនិយាយលេងសើច) ។

14 وَمَا هُوَ بِالْهَزْلِ

១៥. ពិតប្រាកដ ពួកទាំងអស់នោះ (ពួកកាហ្វៀរ) បានធ្វើល្បិចកល មិនល្អនៅ ចិត្ត ។

15 إِنَّهُمْ يَكِيدُونَ كَيْدًا

១៦ ហើយយើង (អល់ឡោះ) មានល្បិចមួយ ដ៏ល្អពិតប្រាកដដែលសមស្របហេតុសមផល — وَأَكِيدُ كَيْدًا ١٦

១៧. ហេតុដូច្នេះហើយ ចូរអ្នកកុំប្រញាប់ប្រញាល់អ្វី ដាក់ទោសបណ្ដា អ្នកគ្មានជំនឿ ណា៎ះ ពន្យាពេលដល់ ពួកវាបន្តិចសិន ណា៎ះ ដ៏បន្តិចសិន — فَمَهِّلِ الْكَافِرِينَ أَمْهِلْهُمْ رُوَيْدًا ١٧

ឱវាទកថាវគ្គ វគ្គនេះមានបញ្ជាក់ អំពីមនុស្សលោកត្រូវរួប ក៏ស្ថិតក្នុងការគ្រប់គ្រង របស់ អល់ឡោះជាម្ចាស់ ។

ដូចនោះដែរ អល់ឡោះ មានបង្កើតជាគ្រាន់ម្ដង ហើយនឹងត្រូវមានបង្កើត ក្រោយពីពេលស្លាប់រួចមកហើយនោះ ។

- ការបញ្ជាក់ អំពី អាល់គួរអាន (القرآن)

អាល់គួរអាន (القرآن) មានលំដាប់លោយឥតខ្ចោះដ៏គតិសារ (លាក្ដី) ច្បាប់ធំ សុលរូលរូបពិភពលោកទាំងអស់ហ្នឹង កុំរង្គាយពាញ់កលល្បិច របស់ បណ្ដាអ្នកដែលគ្មានជំនឿក្នុងសាសនា ។

កន្លែងផ្កាយ البروج

កថាវិត្ត វិត្តនេះគេបានបញ្ចុះនៅ ម៉ាក្កាស់ ដែលមាន២២ឃ្លា ។
គេបានបញ្ចុះវិត្តនេះ ក្រោយពីពេលដែលគេបានបញ្ចុះវិត្ត الشمس
ឈ្មោះ البروج មានន័យថា កន្លែងផ្កាយ
គេយកមកអំពីពាក្យសំដី البروج ដែលមាននៅក្នុងឃ្លាទីមួយ
បង្អស់នៃវិត្តនេះ ។

គោលការណ៍សំខាន់ៗក្នុងន័យរបស់វិត្ត

ប្រកាស និងការអនុវត្តន៍ របស់ បណ្ដា អ្នកគ្មានជំនឿទៅចំពោះ
បណ្ដា អ្នកដែលបានតាម ការទំនាញនាំ របស់ ព្យាការី សន្តិភាពនឹង
មានលើ អល់ឡោះ (ﷺ) ។
កត្តានានាក្នុងការគ្រប់គ្រងរបស់ អល់ឡោះ នោះ ដែលមួយភាគ ។
ពីពសញ្ញា ហើយស្រឡាញ់របស់ អល់ឡោះថា បណ្ដា អ្នកដែល
មានជំនឿនៅម៉ាក្កាស់នោះគង់តែនឹងឈ្នះ ទារុណកម្មទៅលើបណ្ដា
អ្នកទាំងនោះ ដូចជាគេបានធ្វើទារុណកម្មទៅលើក្រុម ហ្យូរីអ៊ីន
និងក្រុមលើមួយដ៏ទៀតនេះដែរ ។
អល់ឡោះ ទ្រង់បានធានា ការពារ និងលើកដំកើង ដ៏ខ្ពង់ខ្ពស់
លើអាល់គួរអាន (القرآن) នេះជានិរន្តរ៍រហូតទៅ ។

البروج

កន្លែងផ្កាយ

بِسْمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ

នឹងព្រះនាម អល់ឡោះ ម្ចាស់ទ្រង់មហា
សាការណ៍ទៀតទ្រង់មហា មេត្តាប្រណី ។

១. (អល់ឡោះ) បានស្បថនឹងមេឃ ដែលមានកន្លែងផ្កាយ ។	وَالسَّمَاءِ ذَاتِ الْبُرُوجِ	١
២ ហើយនឹងថ្ងៃដែលបាន ចុះ កិច្ចសន្យា ។	وَالْيَوْمِ الْمَوْعُودِ	٢
៣. ហើយនឹងអ្នកដែលធ្វើសាក្សី និងអ្នកដែលត្រូវគេធ្វើសាក្សី ។	وَشَاهِدٍ وَمَشْهُودٍ	٣
៤. គេបានធ្វើទារុណកម្មទៅលើពួកដែលគ្រប់គ្រង លើរណ្ដៅ ពន្លឺយានត ។	قُتِلَ أَصْحَابُ الْأُخْدُودِ	٤
៥. ភ្លើង ឆេះឡើង រងើ សន្ធោ ទូល ។	النَّارِ ذَاتِ الْوَقُودِ	٥
៦. ពេលនោះ ហើយ អ្នកទាំងអស់នោះបាន អង្គុយ ជុំវិញពីលើវា ។	إِذْ هُمْ عَلَيْهَا قُعُودٌ	٦
៧. ហើយអ្នកទាំងអស់នោះ បានធ្វើសាក្សី ទៅលើអ្វី ដែលគេកំពុងតែធ្វើទៅចំពោះ អ្នកដែលមានជំនឿ ។	وَهُمْ عَلَىٰ مَا يَفْعَلُونَ بِالْمُؤْمِنِينَ شُهُودٌ	٧
៨. ហើយអ្នកទាំងអស់នោះ (អ្នកគ្មានជំនឿ) មិនមានកំហឹងទេ ទៅលើអ្នកទាំងអស់នោះ (អ្នកដែលមានជំនឿ) លើកលែងតែ អ្នកទាំងអស់នោះ មានជំនឿលើ នឹងអល់ឡោះ ដែលមានមហាអំណាច ទៀតនឹងមហាសរសើរ ។	وَمَا نَقَمُوا مِنْهُمْ إِلَّا أَنْ يُؤْمِنُوا بِاللَّهِ الْعَزِيزِ الْحَمِيدِ	٨

៩. ជំពោះទ្រង់ហើយជាម្ចាស់គ្រប់គ្រង
ឋានទាំងពួង ហើយនិងផែនដី ទៀត
អល់ឡោះជាអ្នកធ្វើសាក្សីទៅលើទាំង
អស់វត្ថុនោះ ។

9 ٱلَّذِى لَهُۥ مُلْكُ ٱلسَّمَٰوَٰتِ وَٱلْأَرْضِ
وَٱللَّهُ عَلَىٰ كُلِّ شَىْءٍ شَهِيدٌ

១០. ពិតប្រាកដ អ្នកដែលបានបៀតបៀនពួកមាន
ជំនឿ បណ្ដាប្រុសទាំង ហើយនិងបណ្ដាស្រី
ទាំង ដែលមានជំនឿ (អ៊ីស្លាម) ក្រោ-
-យមកទាំងអស់នោះ គ្មានសុំ
ទោសទេ ។ ដើម្បីនោះហើយ សម្រាប់
អ្នកទាំងអស់នោះ ទារុណកម្មឋាន
នរកជាហាន់ណាំ ។ ហើយសម្រាប់អ្នកទាំង
អស់នោះ ទារុណកម្មនឹងភ្លើងមហាក្ដៅខ្លាំង

10 إِنَّ ٱلَّذِينَ فَتَنُوا۟ ٱلْمُؤْمِنِينَ
وَٱلْمُؤْمِنَٰتِ ثُمَّ لَمْ يَتُوبُوا۟
فَلَهُمْ عَذَابُ جَهَنَّمَ وَلَهُمْ
عَذَابُ ٱلْحَرِيقِ

១១. ពិតប្រាកដ អ្នកដែលមានជំនឿទាំងអស់
នោះ ហើយបានប្រកបកិច្ចការល្អ
ល្អៗ ។ សម្រាប់អ្នកទាំងអស់នោះ
ទុកបានឋានសួគ៌ ដែលហូរនៅពីក្រោមវា
នោះ ជាទន្លេៗច្រើន នៃនោះហើយ
ជាជ័យជំនះដ៏មហាធំបំផុត ។

11 إِنَّ ٱلَّذِينَ ءَامَنُوا۟ وَعَمِلُوا۟
ٱلصَّٰلِحَٰتِ لَهُمْ جَنَّٰتٌ تَجْرِى
مِن تَحْتِهَا ٱلْأَنْهَٰرُ ذَٰلِكَ
ٱلْفَوْزُ ٱلْكَبِيرُ

១២. ពិតប្រាកដ ទារុណកម្មរបស់ម្ចាស់អ្នកនោះ
ពិតមហាខ្លាំងក្លៃ ។

إِنَّ بَطْشَ رَبِّكَ لَشَدِيدٌ 12

១៣. ពិតប្រាកដ ទ្រង់នោះហើយ អ្នកដែលបង្កើត
ហើយដែលបង្វិលត្រឡប់ ។

إِنَّهُۥ هُوَ يُبْدِئُ وَيُعِيدُ 13

១៤ ហើយទ្រង់ មហាអភ័យទោស និង មហាស្រឡាញ់ ។ — وَهُوَ الْغَفُورُ الْوَدُودُ ١٤

១៥. អ្នកដែលគ្រប់គ្រងរាជ្យ ដ៏មហាថ្កុំថ្កើង ។ — ذُو الْعَرْشِ الْمَجِيدُ ١٥

១៦. អ្នកដែលមានមហាអំណាច ធ្វើអ្វីៗ តាមដែលទ្រង់ចង់ ។ — فَعَّالٌ لِمَا يُرِيدُ ١٦

១៧. តើបានមកដល់អ្នកនូវដំណឹងពួក ពលទាហាន ពីពួកមុនៗទេ ។ — هَلْ أَتَاكَ حَدِيثُ الْجُنُودِ ١٧

១៨. ក្រុមហ្វៀរអោន ហើយនិងសាមូដ ។ — فِرْعَوْنَ وَثَمُودَ ١٨

១៩. ផ្ទុយទៅវិញ បណ្ដាអ្នកដែលគ្មានជំនឿនោះ ពួកគេនៅតែស្ថិតក្នុងការភូតកុហក ។ — بَلِ الَّذِينَ كَفَرُوا فِي تَكْذِيبٍ ١٩

២០ ហើយអល់ឡោះ បានឡោមព័ទ្ធពីក្រោយ ពួកគេ អ្នកទាំងអស់នោះ ។ — وَاللَّهُ مِنْ وَرَائِهِمْ مُحِيطٌ ٢٠

២១. ពិតប្រាកដ គម្ពីរ គួរអាន (កូរអាន) ដ៏មហាថ្កុំថ្កើង ។ — بَلْ هُوَ قُرْآنٌ مَجِيدٌ ٢١

២២ នៅក្នុងក្ដារឡោះ (លូហ៍ម៉ះហ្វូស) ដែលគេរក្សាការពារ ។ — فِي لَوْحٍ مَحْفُوظٍ ٢٢

ចប់ពាក់កណ្ដាល ក្នុងនេះបានបញ្ចាំង អំពីប្រភព របស់អ្នកដែលល្អ

ជំនឿ ទៀតផង បានប្រព្រឹត្ត ទៅលើបណ្តាអ្នកដែលតាមការ រំពារពារបស់
ព្រលឹង ។ ហើយនិងបញ្ជាក់ រំពាត់ទៅលើបណ្តាអ្នកដែលធ្វើល្អពីមុនៗមក

ក្រោយមក ព្រលឹងទាំងនោះ បានអោយគាសញ្ញា ទៅលើការធ្វើដំណើរនៃវត្តី
ស្ដុបនៃសុបិន របស់បណ្តាអ្នកមានជំនឿ ហើយនិងការធ្វើព្យាករណ៍ ទៅលើ
បណ្តាអ្នកដែលគ្មានជំនឿនោះ ដើម្បីនិងល្បងលោម សាវ៉ះ(ណាត់) និង
សត្វភព្វ ហើយនិងអ្នកដែលតាម ព្រលឹងទាំងនោះ ក្នុងការរុបនុលដែល រំលោភ
ទៅលើរបស់បណ្តា អ្នកដែល នៅលើកាស់នោះ ។

ការធ្លាក់បែក　　الانشقاق

កថាវគ្គ ៖ វគ្គនេះគេបានបញ្ចុះនៅម៉ាក្កាស់ ដែលមាន ២៥ ឃ្លា ។
គេបានបញ្ចុះវគ្គនេះ ក្រោយពីពេលដែលគេបានបញ្ចុះវគ្គ الانفطار
ឈ្មោះ الانشقاق មានន័យថា ការធ្លាក់បែក
គេយកឈ្មោះពីពាក្យសំដី انشقت ដែលមាននៅក្នុងឃ្លាដំបូងបង្អស់
នៃវគ្គនេះ ។

គោលការណ៍សំខាន់ៗក្នុងន័យរបស់វគ្គ

ពត៌មានអំពី ដែលជាប់មានទៀង នៅថ្ងៃនោះកាល ។
ការវិនាស ពាក្យប្រាកដ មនុស្សយើងរមែងតែងតែមានរូប សត្វ
លំបាក វេទនា ដើម្បីជឿនឹងលើរចនារូប ម្ចាស់របស់គេនោះ ។
ការជួបពាល់ម្ចាស់របស់គេនេះឯង ប្រាកដតែងតែនឹងជួបមិនខានឡើយ ។
- មានអ្នកខ្លះទទួលដោយងាយ ខ្លះទៀតក៏ទទួលការលំបាកវេទនា
ជាមួយនឹងនៅមួយជាតិ ការបញ្ចប់ ហើយនិងការរស់នៅក្នុង
លោក ហើយនិងនៅថ្ងៃបរលោក ។

الانشقاق

ការធ្លាក់បែក

بِسْمِ اللَّهِ الرَّحْمَنِ الرَّحِيمِ

និងព្រះនាម អល់ឡោះ ម្ចាស់ទ្រង់មហា
សប្បុរសទៀតទ្រង់មហា មេត្តាប្រណី ។

١ إِذَا السَّمَاءُ انْشَقَّتْ

១. ពេលណាមេឃបានធ្លាក់បែក

២. ហើយវាបានយល់ព្រមដល់ព្រះម្ចាស់ របស់វា ហើយគេបានអនុញ្ញាតិដល់វា ។ | وَأَذِنَتْ لِرَبِّهَا وَحُقَّتْ ٢

៣. ហើយពេលណាដែនដី គេធ្វើបានលាតត្រដាង ។ | وَإِذَا الْأَرْضُ مُدَّتْ ٣

៤ ហើយវាបានក្រវាត់ក្រវែងចេញ អ្វីៗ ដែលនៅក្នុងវា ហើយវាបានស្ងះស្រឡះ ស្អាត ។ | وَأَلْقَتْ مَا فِيهَا وَتَخَلَّتْ ٤

៥. ហើយវាបានយល់ព្រមទៅដល់ព្រះម្ចាស់របស់វា ហើយគេបានអនុញ្ញាតិដល់វា | وَأَذِنَتْ لِرَبِّهَا وَحُقَّتْ ٥

៦. ឱ មនុស្សលោកអើយ ពិតប្រាកដឯង បានខិតខំប្រឹងប្រែងប្រកបកិច្ចការ ទៅចំពោះម្ចាស់ឯង គឺប្រាកដពិតប្រាកដ ហើយបានជា ឯងនឹងជួបលទ្ធផល របស់ឯង ។ | يَا أَيُّهَا الْإِنْسَانُ إِنَّكَ كَادِحٌ إِلَىٰ رَبِّكَ كَدْحًا فَمُلَاقِيهِ ٦

៧. ហើយឯអ្នកបានទទួល នូវសៀវភៅ គេឲ្យនូវ បញ្ជី កិច្ចប្រតិបត្តិនៅដៃស្តាំរបស់គាត់ | فَأَمَّا مَنْ أُوتِيَ كِتَابَهُ بِيَمِينِهِ ٧

៨. ឯអ្នកនោះ គង់តែគេនឹងជំនុំជម្រះ វាតាមជំនុំជម្រះ ដោយការងាយស្រួល ។ | فَسَوْفَ يُحَاسَبُ حِسَابًا يَسِيرًا ٨

៩. ហើយគេនឹងវិលត្រឡប់ទៅចំពោះគ្រួសាររបស់គេ ដោយសប្បាយរីករាយ ។ وَيَنقَلِبُ إِلَىٰٓ أَهْلِهِۦ مَسْرُورًا ٩

១០ ហើយឯអ្នកនោះដែល ដៃលោកសណ្តាំដែល គេអោយ សៀវភៅ(បញ្ជីកិច្ចប្រតិបត្តិ)គេ ពីក្រោយខ្នងគេ ។ وَأَمَّا مَنْ أُوتِىَ كِتَٰبَهُۥ وَرَآءَ ظَهْرِهِۦ ١٠

១១ ដូច្នេះ គេគង់នឹងស្រែកហៅ នូវការវិនាសរលួយ ។ فَسَوْفَ يَدْعُوا۟ ثُبُورًا ١١

១២. ហើយ គេនឹងចូលក្នុងភ្លើងដែលកំពុងឆេះឆាបឆេះ ។ وَيَصْلَىٰ سَعِيرًا ١٢

១៣. ពិតប្រាកដ កាលពីលើលោកនេះ(ក្នុងលោក) ក្នុងគ្រួសាររបស់គេ ដោយការសប្បាយរីករាយ ។ إِنَّهُۥ كَانَ فِىٓ أَهْلِهِۦ مَسْرُورًا ١٣

១៤. ពិតប្រាកដ គេមានសញ្ញាណគិតថា គេគ្មាននឹងវិលត្រឡប់ទេ (ទៅចំពោះអល់ឡោះក្រោយពីគេស្លាប់) ។ إِنَّهُۥ ظَنَّ أَن لَّن يَحُورَ ١٤

១៥. ពុំមែនដូច្នោះទេ ពិតប្រាកដ ម្ចាស់របស់គេមានឃើញច្បាស់បរិបូណ៌ ។ بَلَىٰٓ إِنَّ رَبَّهُۥ كَانَ بِهِۦ بَصِيرًا ١٥

១៦. ទើបពិតប្រាកដ អញមានស្បថនឹងពន្លឺក្រហមរៀបធ្លាក់ពេលល្ងាច ។ فَلَآ أُقْسِمُ بِٱلشَّفَقِ ١٦

១៧. ហើយ(អល់ឡោះ)បានស្បថនឹងពេលរាត្រី ហើយនឹងវត្ថុនានាដែលបានប្រមូលផ្តុំ ។	وَالَّيْلِ وَمَا وَسَقَ	١٧
១៨. ហើយ(អល់ឡោះ)បានស្បថនឹងព្រះចន្ទ ពេលណាវាបានពេញពន្លឺបូរមី	وَالْقَمَرِ إِذَا اتَّسَقَ	١٨
១៩. ពិតប្រាកដ ពួកឯងទាំងអស់គ្នានឹងប្រែប្រួល ឡើងពីមួយជាន់ទៅមួយជាន់ (ក្នុងការរស់នៅ)	لَتَرْكَبُنَّ طَبَقًا عَن طَبَقٍ	١٩
២០ ហេតុអ្វីទៅដែលនាំអោយពួកទាំងអស់នោះ គ្មានជំនឿជឿស៊ប់ ។	فَمَا لَهُمْ لَا يُؤْمِنُونَ	٢٠
២១. ហើយពេលណាគេសូត្រគម្ពីរ ទៅលើពួកទាំងអស់ វាល់ឃ្លាអាន(القرآن) ពួកទាំងអស់នោះ គ្មានគោរពប្រណិបត្តិតាមទេ	وَإِذَا قُرِئَ عَلَيْهِمُ الْقُرْآنُ لَا يَسْجُدُونَ	٢١
២២. ផ្ទុយទៅវិញ ពួកដែលគ្មានជំនឿទាំងអស់នោះ កំពុងតែភូតភរកុហក	بَلِ الَّذِينَ كَفَرُوا يُكَذِّبُونَ	٢٢
២៣. ហើយតាមការពិត អល់ឡោះមហាដឹងនិងដឹងច្បាស់ អ្វីៗដែលពួកទាំងអស់នោះ កំពុងតែលាក់កំបាំង	وَاللَّهُ أَعْلَمُ بِمَا يُوعُونَ	٢٣
២៤ ទើបបានជា ចូរឯង(មូហាំម៉ាត់)ផ្តល់ដុះ	فَبَشِّرْهُم بِعَذَابٍ أَلِيمٍ	٢٤

ពត៌មានសប្បាយរីករាយ សំរាប់ពួកគេ
របស់គេះ នឹងទារុណកម្មដ៏ឈឺចាប់ ។

២៥ លើកលែងតែ បណ្ដា អ្នកដែលមានជំនឿ
ស្មោះត្រង់ ហើយប្រព្រឹត្តទាំងរបស់គេនោះ
តាមប្រកបនិងគុណនៃសេចក្ដីល្អ សំរាប់
អ្នកទាំងនោះហើយ ផលបុណ្យគ្មានពេល
ដាច់ឡើយ ។ إِلَّا الَّذِينَ آمَنُوا وَعَمِلُوا الصَّالِحَاتِ لَهُمْ أَجْرٌ غَيْرُ مَمْنُونٍ 25

ពិតតកជាវិត្ត. ពាក្យនេះ ប្រាប់បញ្ជាក់ រំលឹកលើកដើមការនិងប្រាប់ឲ្យដឹងនៃ
ថ្ងៃនោះកាល (កិយ៉ាម៉ះ) ។
និងចេញទៅនឹង ការតបស្នងសងពេញលេញ រំលើសុទ្ធនៃនិងអំពើ
ខ្លួននៃគេនោះ ។ ហើយបញ្ចូលទាំងការកើតមានថ្ងៃ នោះកាល ។
ថ្ងៃនោះកាលនេះប្រាកដជាដាច់ខាតការមានមែន ។ ផ្ទុយទៅវិញ
អ្នកដែលគ្មានជំនឿក្នុងសាសនា ត្រូវប្រឆាំងថាគ្មាន ថ្ងៃនោះកាល
(កិយ៉ាម៉ះ) នោះទេ ។

អ្នកកេញប្រវ័ញ្ច المطففين

កថាវគ្គ វគ្គនេះគេបានបញ្ចុះនៅម៉ាក្កាស់ ដែលមាន ៣៦ ឃ្លា គេបានបញ្ចុះវគ្គនេះ ក្រោយពីពេលដែលគេបានបញ្ចុះ វគ្គ العنكبوت /

ឈ្មោះ المطففين មានន័យថា អ្នកកេញប្រវ័ញ្ច គេយកមកពីពាក្យសំដី المطففين ដែលមាននៅក្នុង ឃ្លាទីមួយនៃវគ្គនេះ ។

គោលការណ៍សំខាន់ៗក្នុងន័យរបស់វគ្គ

ស្ថលឈ្មោះ បានប្រទេចង្គាលា ពេជ៌ពោះអ្នកដែលកេញ ប្រវ័ញ្ច ក្នុងការថ្លឹង ឡើតការវាល់ហើយនិងការវាល់ ។

គេបានដាក់ទុក ការសាក្រក់របស់មនុស្សលោក ដែលគេបាន ប្រមូលដាក់ក្នុងសិជ្ជីន (سجين) នៃបញ្ជីអាក្រក់ ។

ផ្ទុយទៅវិញ គេបានដាក់ទុកអំពើល្អបរិសុទ្ធ របស់មនុស្សលោក ដែលគេប្រមូលដាក់ក្នុង អ៊ីលលីយីន (عليين) នៃបញ្ជីល្អ ។

ការតបស្នងនឹងសីលយសិនៈគ្រប់បែបគ្រប់យ៉ាង ចំពោះបណ្ដា អ្នកដែលបានប្រព្រឹត្តអំពើល្អ ។

អ្នកតា ហើយនិងការមើលងាយមើលដោករបស់បណ្ដា អ្នកដែលគ្មានជំនឿជឿសាសនាក្នុងលោក នៅចំពោះបណ្ដាអ្នក ដែលមានជំនឿជឿសាសនា ។

អ្នកតា ចំអកឡកឡឿយរបស់បណ្ដាអ្នកមានជំនឿក្នុងសាសនា នៅឯថ្ងៃបរលោក ទៅចំពោះបណ្ដាអ្នកដែលគ្មានជំនឿក្នុងសាសនា នោះវិញ ។

المطففين

ស៊ូភាភៃភាញប្រឆ័ញ

ដោយព្រះនាម អល់ឡោះ ម្ចាស់ដ៏មហា សាការុណ ទៀតដ៏មហាមេត្តាប្រណី ។

بِسْمِ اللَّهِ الرَّحْمَـٰنِ الرَّحِيمِ

១. វិនាសអន្តរាយហើយសំរាប់អ្នកបោកបញ្ឆោត

١ وَيْلٌ لِّلْمُطَفِّفِينَ

២ បណ្ដាអ្នកទាំងនោះ ពេលណាគេ វាល់យកពី
មនុស្សលោក គេទាំងអស់នោះ ចង់បានគ្រប់

٢ الَّذِينَ إِذَا اكْتَالُوا عَلَى
النَّاسِ يَسْتَوْفُونَ

៣. ហើយពេលណាអ្នកទាំងអស់នោះ បានវាល់
ទៅឲ្យគេ ឬមួយបានថ្លឹងទៅឲ្យគេ
វិញ អ្នកទាំងអស់នោះ បានធ្វើឲ្យខ្វះ
(ខ្នាតវាល់និងថ្លឹង)

٣ وَإِذَا كَالُوهُمْ أَو وَّزَنُوهُمْ
يُخْسِرُونَ

៤. តើ គេមិនគិតទេឬ? អ្នកទាំងអស់នោះ គ្មាន
សញ្ជឹងគិត ពិតប្រាកដ អ្នកទាំងអស់នោះ គេ
នឹងប្រោសឡើងវិញ

٤ أَلَا يَظُنُّ أُولَـٰئِكَ أَنَّهُم مَّبْعُوثُونَ

៥. នៅថ្ងៃដ៏មហាធំ

٥ لِيَوْمٍ عَظِيمٍ

៦. គឺថ្ងៃ ដែលមនុស្សលោកក្រោកឈរ ចំ
ពោះទៅម្ចាស់ ពិភពលោក ។

٦ يَوْمَ يَقُومُ النَّاسُ لِرَبِّ الْعَالَمِينَ

៧. កុំធ្វើដូចនោះទេ ពិតប្រាកដ បញ្ជីអ្នក
ទាំងអស់ ដែលបានប្រព្រឹត្តអំពើទុច្ចរិតនោះ

٧ كَلَّا إِنَّ كِتَابَ الْفُجَّارِ لَفِي سِجِّينٍ

ពិភពមានទៅក្នុង ស៊ុជជីន (سجين)

៨ ហើយអ្នកដឹងដែរឬទេ ថាអ្វីទៅ ស៊ុជជីន (سجين) នោះ — 8 وَمَا أَدْرٰكَ مَا سِجِّيْنٌ

៩. វានោះគឺ បញ្ជីដែលគេបានចារទុក — 9 كِتٰبٌ مَّرْقُوْمٌ

១០ វិនាសអន្តរាយហើយ នៅថ្ងៃនោះ ចំពោះអ្នកទាំងអស់ ដែលកុហក — 10 وَيْلٌ يَّوْمَئِذٍ لِّلْمُكَذِّبِيْنَ

១១ បណ្ដាអ្នកដែលកុហកនឹងថ្ងៃតបស្នង — 11 الَّذِيْنَ يُكَذِّبُوْنَ بِيَوْمِ الدِّيْنِ

១២. ហើយគ្មាន កុហកនឹងវាទេ លើកលែង តែពួកបណ្ដាអ្នកដែលបំពានច្បាប់ហើយ ទុច្ចរិតផង — 12 وَمَا يُكَذِّبُ بِهٖٓ إِلَّا كُلُّ مُعْتَدٍ أَثِيْمٍ

១៣. ពេលណាគេបានសូត្រវិវរណៈ ហើយទៅលើវា នូវប៉ុន្មានវាក្យ គួរអាន (آيات) របស់យើងទៀត វាបាននិយាយថា នេះគឺរឿងព្រេងរបស់មនុស្ស ដែលគេប្រាប់តៗគ្នាទេ។ — 13 إِذَا تُتْلٰى عَلَيْهِ اٰيٰتُنَا قَالَ أَسٰطِيْرُ الْأَوَّلِيْنَ

១៤ មិនមែនដូច្នោះទេ ពិតប្រាកដ ការសងកម្ម គ្របដណ្ដប់ ហើយទៅលើចិត្តអ្នកទាំងអស់ នោះ ដោយសារតែទុច្ចរិតដែលអ្នកទាំងអស់នោះ បានប្រព្រឹត្តរួចមកហើយ ។ — 14 كَلَّا بَلْ رَانَ عَلٰى قُلُوْبِهِمْ مَّا كَانُوْا يَكْسِبُوْنَ

១៥. កុំដូច្នេះនោះទេ ពិតប្រាកដ ពួកគេទាំងអស់
នោះ នៅថ្ងៃនោះ ម្ចាស់របស់ពួកគេទាំងអស់
នោះ ត្រូវគេបាំងហើយ រវាងម្ចាស់របស់វា ។

كَلَّا إِنَّهُمْ عَن رَّبِّهِمْ يَوْمَئِذٍ لَّمَحْجُوبُونَ ١٥

១៦ បន្ទាប់មក ពិតប្រាកដ ពួកគេទាំងអស់នោះ
ច្បាស់ជាចូលទៅក្នុង ឋាននរក [illegible]
(الجحيم) ។

ثُمَّ إِنَّهُمْ لَصَالُوا الْجَحِيمِ ١٦

១៧. បន្ទាប់មកគេប្រាប់ថា នេះហើយ
កាលពីមុន ពួកឯងទាំងអស់គ្នា នេះបានកុហក
កុហកនឹងវា ([illegible])

ثُمَّ يُقَالُ هَٰذَا الَّذِي كُنتُم بِهِ تُكَذِّبُونَ ١٧

១៨. កុំដូច្នេះនោះទេ ពិតប្រាកដបញ្ជី
អ្នកទាំងអស់ដែលបានប្រព្រឹត្ត អំពើល្អទៀត
នោះ ពិតជាបានដាក់នៅក្នុង អ៊ិល្លី
យីន (កន្លែងដ៏ខ្ពង់ខ្ពស់)

كَلَّا إِنَّ كِتَابَ الْأَبْرَارِ لَفِي عِلِّيِّينَ ١٨

១៩. តើពួកឯងបានដឹងដែរឬទេ ? ថាតើ
អ៊ិល្លីយូន (عليون) នោះ ?

وَمَا أَدْرَاكَ مَا عِلِّيُّونَ ١٩

២០ បញ្ជី ដែលគេបានចារទុក

كِتَابٌ مَّرْقُومٌ ٢٠

២១. បានធ្វើសាក្សីហើយ ដោយពួកទេវៈ
(مقربون) ដែលនៅជិត(ព្រះអល់
ឡោះ) ។

يَشْهَدُهُ الْمُقَرَّبُونَ ٢١

២២. ពិតប្រាកដ ពួកដែលល្អប្រពៃនឹងនៅ
ស្ថិតក ប្រាកដជាបានចូលនៅក្នុងឋានសួគ៌
ណាអុីម (نعيم)

إِنَّ الْأَبْرَارَ لَفِي نَعِيمٍ 22

២៣. ពួកទាំងអស់នោះអង្គុយលើគ្រែលំអរ
តាក់ កំពុងតែគយគន់

عَلَى الْأَرَائِكِ يَنظُرُونَ 23

២៤ ឯងនឹងឃើញ នៅទឹកមុខពួកទាំងអស់
នោះស្រស់ ប្រិមប្រិយ ពោរពេញទៅ
ដោយក្ដីសប្បាយរីករាយ

تَعْرِفُ فِي وُجُوهِهِمْ نَضْرَةَ النَّعِيمِ 24

២៥ គេ ឲ្យពួកទាំងអស់នោះផឹកស្រា ត្រា
ដ៏ បរិសុទ្ធ

يُسْقَوْنَ مِن رَّحِيقٍ مَّخْتُومٍ 25

២៦. បរិសុទ្ធ វានោះ មានត្រាបិទប្រក្លិនឈ្ងុយ
ដូចជាក្លិនប្រេង មិស្ក (مسك) ហើយនៅក្នុង
ការនេះនោះ . ទើបបានជា ប្រុប
ណាចង់ប្រជែងប្រណាំង ពួកទាំងអស់ដែលបាន
ប្រណាំងប្រជែងនោះ ។

خِتَامُهُ مِسْكٌ وَفِي ذَٰلِكَ
فَلْيَتَنَافَسِ الْمُتَنَافِسُونَ 26

២៧. ហើយលាយជាមួយរបស់ស្រានោះ
តេសនីម (تسنيم)

وَمِزَاجُهُ مِن تَسْنِيمٍ 27

២៨. គឺប្រភពទឹក ដែលផឹក ... ពួក
ដែលនៅជិត(ចំពោះ អល់ឡោះ)

عَيْنًا يَشْرَبُ بِهَا الْمُقَرَّبُونَ 28

២៩. ពិតប្រាកដណាស់ អស់អ្នកដែលបានប្រព្រឹត្ត
អំពើខុសឆ្គង កាលពីមុនមក អ្នកទាំង
អស់នោះបានសើចចំអកឡកឡឿយ ចំពោះ
អ្នកដែលមានជំនឿទាំងអស់ ។

إِنَّ الَّذِينَ أَجْرَمُوا كَانُوا ٢٩
مِنَ الَّذِينَ آمَنُوا يَضْحَكُونَ

៣០- ហើយពេលណាបានដើរកាត់ (អ្នកមូមីន)
ពីមុខអ្នកទាំងអស់នោះ អ្នកទាំងនោះ
បានពេបជ្រាយ[illegible] ។

وَإِذَا مَرُّوا بِهِمْ يَتَغَامَزُونَ ٣٠

៣១. ហើយពេលណា អ្នកទាំងអស់បានវិល
ត្រឡប់ទៅឯគ្រួសាររបស់គេនោះ
អ្នកទាំងនោះបានវិលត្រឡប់ទៅដោយក្ដី
សប្បាយរីករាយ ។

وَإِذَا انْقَلَبُوا إِلَىٰ أَهْلِهِمُ ٣١
انْقَلَبُوا فَكِهِينَ

៣២ ហើយពេលណាអ្នកទាំងអស់នោះបាន
ឃើញពួកអ្នកដែល (មូមីន) អ្នកទាំងនោះ
ពោលថា ពិតប្រាកដណាស់អ្នក ទាំងអស់នេះ
ពិតជាវង្វេង ។

وَإِذَا رَأَوْهُمْ قَالُوا إِنَّ هَٰؤُلَاءِ ٣٢
لَضَالُّونَ

៣៣. ដែលពួកនោះ គេគ្មានបញ្ជូនទេ អ្នកទាំង
អស់. (អ្នកគ្មានជំនឿ) [illegible]
លើអ្នកទាំងអស់នោះ (អ្នកមូមីន) ។

وَمَا أُرْسِلُوا عَلَيْهِمْ حَافِظِينَ ٣٣

៣៤ ដូច្នេះបានជា ថ្ងៃនោះ បណ្ដាអ្នកមាន
ជំនឿបានសើចចំអកឡកឡឿយ ទៅចំពោះ
បណ្ដាអ្នកដែលគ្មានជំនឿ (الكفار) ។

فَالْيَوْمَ الَّذِينَ آمَنُوا مِنَ الْكُفَّارِ ٣٤
يَضْحَكُونَ

៣៥. អ្នកទាំងអស់នោះ សម្លឹង នៅលើគ្រែ នានា ក៏ឃើញផែកគយបរិវ — عَلَى ٱلْأَرَآئِكِ يَنظُرُونَ ٣٥

៣៦. តើគេបានតបស្នងទៅលើបណ្ដាអ្នកគ្មាន ជំនឿដែរឬទេ? អ្វីៗដែលអ្នកទាំងអស់ នោះ បានប្រព្រឹត្តរួចមកហើយ។ — هَلْ ثُوِّبَ ٱلْكُفَّارُ مَا كَانُوا۟ يَفْعَلُونَ ٣٦

ប៉ិតកប៉ាវិត្ត វគ្គនេះបានបង្ហាញប្រមូលផ្ដុំ បញ្ចប់នូវការក្រោយដែល ទៅចំពោះបណ្ដាអ្នកដែលគ្មានជំនឿក្នុងសាសនា ហើយនឹងបណ្ដាអ្នក ដែលបានប្រព្រឹត្តអំពើទុច្ចរិតក្នុងការលោកិយ ព្រោះអាល្លោះ ក៏បាន បញ្ជាក់ អំពើកិច្ចសន្យា របស់ ព្រះអល់ឡោះ ក្នុងការប្រទានផ្ដល់ទោស ដល់ចំពោះបណ្ដាអ្នកដែលគ្មានជំនឿ ទៀតបានប្រព្រឹត្តហើយនូវអំពើល្អនឹង លោះស ។

ការបែកខ្ទេក الانفطار

កាលវិគ្គ វគ្គនេះគេបានបញ្ចុះនៅម៉ិកកាស់ ដែលមាន ១៩ បន្ទ ។
គេបានបញ្ចុះវគ្គនេះ ក្រោយពីពេលដែលគេបានបញ្ចុះវគ្គ النازعات
ឈ្មោះ الانفطار គេបានដាក់ជាឈ្មោះដើមនៅក្នុងវគ្គនេះ ដោយសារមាន
ពាក្យកើតឡើងដំបូង انفطرت ដែលមាននៅក្នុងបន្ទាត់ដំបូងបង្អស់នៃវគ្គនេះ ។

គោលការណ៍ដ៏សំខាន់ៗក្នុងន័យរបស់វគ្គ

- ពត៌មាន ដែលកើតមានឡើង នៅក្នុងថ្ងៃបរលោក ។
- សេចក្តីរំឭកទៅដល់ពោះមនុស្សលោក ដើម្បីកុំអោយគាត់ភ្លេចគុណ ការល្អបញ្ចោគរបស់គេ រហូតទាល់តែខ្លួនក្លាយក្លាយទៅជាអ្នកអកតញ្ញូ ប្រឆាំងនឹងព្រះអល់ឡោះជាម្ចាស់របស់គេ ព្រោះ បណ្តាពពួក (ملائكة) ដែលទៅខ្ចាស់ជាន់ឲ្យប្រចាំការនៅ រក្សា ការពារ និងកត់ត្រានូវ អំពើកិច្ចការរបស់មនុស្សលោក ដែលបានប្រព្រឹត្ត ។

នៅថ្ងៃនោះកាល មនុស្សលោក គ្មានលទ្ធភាព អាច ជួយសង្គ្រោះ ទៅដល់ពោះអ្នកដទៃណាមួយទៀតបានឡើយ ។ មានតែ ឫទ្ធានុភាពរបស់ព្រះអល់ឡោះជាម្ចាស់ ប៉ុណ្ណោះ ដែលអាចជួយរៀបចំ គ្រប់ថែបគ្រប់យ៉ាង ។

الانفطار
ការបែកខ្ទេក

ដោយព្រះនាមអល់ឡោះម្ចាស់ដ៏មហា សាងករុណា ដ៏មហាមេត្តាប្រណី ។

بِسْمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ

ពេលណាមេឃបានបែកខ្ទេក

1 إِذَا السَّمَاءُ انْفَطَرَتْ

2 وَإِذَا الْكَوَاكِبُ انْتَثَرَتْ

២ ហើយបណ្ដាផ្កាយទាំងឡាយធ្លាក់ព្រោង
ព្រាត

3 وَإِذَا الْبِحَارُ فُجِّرَتْ

៣. ហើយពេលណាបណ្ដាសមុទ្រទាំងអស់ ត្រូ
វបានធ្វើអោយ ផុះកព្រោលឡើង

4 وَإِذَا الْقُبُورُ بُعْثِرَتْ

៤. ហើយពេលណាផ្នូរទាំងអស់ត្រូវបានបំបះ
ឡើង

5 عَلِمَتْ نَفْسٌ مَا قَدَّمَتْ وَأَخَّرَتْ

៥. បាននឹងដឹងហើយរាល់ៗបណ្ដាជីវិតទាំងឡាយនូវ
អ្វីដែលវាបានធ្វើរួចមកហើយ ។
ហើយអ្វីដែលវាបានទុកក្រោយ ។

6 يَا أَيُّهَا الْإِنْسَانُ مَا غَرَّكَ بِرَبِّكَ الْكَرِيمِ

៦. ឱ!មនុស្សលោកអើយ អ្វីទៅដែលវាបាន
បោកបញ្ឆោតឯង (ចាស់ដែលឯងសុខចិត្ត)?
នឹងម្ចាស់របស់ឯង ដ៏មហាឧត្ដម ។

7 الَّذِي خَلَقَكَ فَسَوَّاكَ فَعَدَلَكَ

៧. ទ្រង់បានបង្កើតឯង ហើយទ្រង់បានបំពេ
-ញលក្ខណៈឯង ហើយទៀតទ្រង់បានពង្រឹង
សំណង់ឯងអោយសមរម្យ

8 فِي أَيِّ صُورَةٍ مَا شَاءَ رَكَّبَكَ

៨. នៅក្នុងសភាពរូបរាងកាយ បែបណា
ក៏ដោយ តាមចិត្តទ្រង់ចង់ ទ្រង់ក៏បាន
រៀបចំរូបឯង ។

9 كَلَّا بَلْ تُكَذِّبُونَ بِالدِّينِ

៩. មិនមែនទ្រង់តែងប្រៀបទេ ផ្ទុយទៅវិញ

អ្នកទាំងអស់គ្នានោះ ភូតភរកុហក នឹង
ថ្ងៃជំនុំជំរះ ។

១០ ហើយពិតប្រាកដ លើឯងទាំងអស់គ្នា ពិតជាមាន អ្នកពិនិត្យមើល ។	١٠ وَإِنَّ عَلَيْكُمْ لَحَـٰفِظِينَ
១១. បណ្ដាអ្នកដ៏ថ្លៃថ្នូរ (ចំពោះអល់ឡោះ) ដែលបានសរសេរទុក (អ្វីៗដែលអ្នកឯង បានប្រព្រឹត្ត) ។	١١ كِرَامًا كَـٰتِبِينَ
១២. អ្នកទាំងអស់នោះ បានដឹងរឿងៗ ដែលអ្នក ឯងទាំងអស់គ្នា បានប្រព្រឹត្ត ។	١٢ يَعْلَمُونَ مَا تَفْعَلُونَ
១៣. ពិតប្រាកដ បណ្ដាអ្នកដែលប្រព្រឹត្តអំពើ សុចរិត ប្រាកដជានឹងបានចូលទៅក្នុងឋាន សួគ៌ ណាអ៊ីម (نعيم) ជាមិនខាន ។	١٣ إِنَّ الْأَبْرَارَ لَفِى نَعِيمٍ
១៤. ហើយពិតប្រាកដ បណ្ដាអ្នកដែលប្រព្រឹត្ត អំពើទុច្ចរិត ប្រាកដជានឹងបានចូលទៅ ក្នុងឋាននរក ជើហ៊ីម (جحيم) ជាមិនខាន ។	١٤ وَإِنَّ الْفُجَّارَ لَفِى جَحِيمٍ
១៥. អ្នកទាំងអស់នោះ នឹងចូលទៅក្នុងវា នៅថ្ងៃជំនុំជំរះ ។	١٥ يَصْلَوْنَهَا يَوْمَ الدِّينِ
១៦. ហើយពួកគេមិនអាចគេច អ្នកទាំងអស់ នោះរួចពីវា (ឋាននរក) ។	١٦ وَمَا هُمْ عَنْهَا بِغَائِبِينَ

១៧. ហើយតើអ្នកឯងបានដឹងដែរឬទេ ?
អ្វីទៅ ថ្ងៃវិនិច្ឆ័យនោះ ?

وَمَآ أَدْرَىٰكَ مَا يَوْمُ ٱلدِّينِ ١٧

១៨. បន្ទាប់មកទៀត តើអ្នកឯងបានដឹងដែរ
ឬទេ ? អ្វីទៅថ្ងៃវិនិច្ឆ័យនោះ ។

ثُمَّ مَآ أَدْرَىٰكَ مَا يَوْمُ ٱلدِّينِ ١٨

១៩. គឺថ្ងៃគ្មាន អ្នកណា ម្នាក់មានអំណាចអ្វី
ឡើយ ចំពោះអ្នកដទៃ, ហើយទាំង
អស់កិច្ចការក្នុងថ្ងៃនោះ ក្នុងការគ្រប់គ្រង
របស់ អល់ឡោះ ។

يَوْمَ لَا تَمْلِكُ نَفْسٌ لِّنَفْسٍ شَيْـًٔا وَٱلْأَمْرُ يَوْمَئِذٍ لِّلَّهِ ١٩

បិតាកបាវិគ្គ រគ្គនេះបានផ្ទះបញ្ជាក់ពីហេតុការណ៍ ដែលកើតមាន ឡើងនៅក្នុងថ្ងៃនោះកាល ហើយបានបញ្ជាក់ពីពិការ បដិសេធ ប្រឆាំង របស់មនុស្សលោកពោះចំពោះការប្រមាថ ដោយឥតអៀន ក្តីសុខ និងជម្ងឺ របស់ អល់ឡោះទៅឯមនុស្សលោកនោះ ។

ដោយហេតុនេះ កិច្ចការរបស់អ្នកទាំងអស់ដែលបានប្រព្រឹត្តនោះ នឹងគេនឹងបានទទួលការតបស្នងវិញមិនខានឡើយ ។

ការមូរផ្តុំ التكوير

កថាវិគ្គ វគ្គនេះគេបញ្ចុះនៅម៉ក្កា ដែលមាន ២៩ ឃ្លា
គេបានបញ្ចុះវគ្គនេះក្រោយពីពេលដែលគេបានបញ្ចុះវគ្គ اللهب
ឈ្មោះ التكوير មានន័យថា ការមូរផ្តុំ
គេយកមកអំពីពាក្យសំដី كورت ដែលមាននៅក្នុងឃ្លាដំបូង
បង្អស់នៃវគ្គនេះ ។

គោលការណ៍ ដ៏សំខាន់ៗក្នុងន័យរបស់វគ្គ

ការរំលាយញាប់ញ័រ ដែលកើតមានឡើង នៅថ្ងៃឆេះកាល ។
នាថ្ងៃនោះគ្រប់ៗវិញ្ញាណ គង់តែនឹងដឹងនូវអ្វីៗដែលខ្លួនបានប្រព្រឹត្ត
រួចមកហើយ នៅក្នុងលោកនោះ ។
ព្រះគម្ពីរ អាល់គួរអាន (القرآن) គឺពាក្យសំដីរបស់ អុលឡោះ ។
តាមរយៈអ៊ើះ (ملك) ជីប្រៀល ដោយបានបញ្ជាក់យ៉ាងច្បាស់
ថា សាវ៉ា (ណាប៊ី) មូហាំម៉ាត់នោះ ជាអ្នកភក្ដីនូវ បំរើអុលឡោះ ។
ព្រះគម្ពីរ អាល់គួរអាន ជាគ្រឿងគ្រប់គ្រាន់ប៉ះបញ្ចាំង បង្ហាញនូវបញ្ហា
របស់មនុស្សលោក ដែលមានចិត្តជំរំរស់នៅក្នុងការស្មោះត្រង់ ។
លោកដើរយ៉ាងនៃក្ដីសុខដុមរមនាក្នុងការរស់នៅរបស់មនុស្សលោក ពិតមាន
ឡើង បាន៉ាងត្រឹមត្រូវនោះ ក៏ដោយសារមកអំពីការផ្ដល់បង្ហាញពី
អុលឡោះជាម្ចាស់នៃ ។

التكوير
ការមូរផ្តុំ

ដោយព្រះនាមអុលឡោះ ម្ចាស់ប្រណីបា بِسْمِ اللَّهِ الرَّحْمَنِ الرَّحِيمِ

សាររាត់ទៀតក្រឡង់បរមា បេស្កាប្រណី

១. ពេលណាហើយ ព្រះអាទិត្យ គេបានរុំវា — إِذَا الشَّمْسُ كُوِّرَتْ ١

២ ហើយពេលណាផ្កាយទាំងអស់បានធ្លាក់ (ដោយព្រាត់ព្រាត) ។ — وَإِذَا النُّجُومُ انْكَدَرَتْ ٢

៣. ហើយពេលណាភ្នំទាំងឡាយ គេបានបណ្តោះវា (រសាត់តាមខ្យល់) ។ — وَإِذَا الْجِبَالُ سُيِّرَتْ ٣

៤ ហើយពេលណាសត្វអូដ្ឋទាំងឡាយ ដែលជើង គេគិតរវីរវល់ ។ — وَإِذَا الْعِشَارُ عُطِّلَتْ ٤

៥. ហើយពេលណាសត្វសាហាវទាំងឡាយ គេបានប្រមូលផ្តុំ — وَإِذَا الْوُحُوشُ حُشِرَتْ ٥

៦ ហើយពេលណា សមុទ្រទាំងអស់ គេបានធ្វើអោយពុះកញ្ជ្រោលឡើង — وَإِذَا الْبِحَارُ سُجِّرَتْ ٦

៧. ហើយពេលណាវិញ្ញាណទាំងអស់ គេបានបង្រួបបង្រួមវិញ ។ — وَإِذَا النُّفُوسُ زُوِّجَتْ ٧

៨. ហើយពេលណាទារកភេទស្រីទាំងអស់ ដែលគេកប់ទាំងរស់នោះ គេបានសួរ — وَإِذَا الْمَوْءُودَةُ سُئِلَتْ ٨

៩. ដោយសារបាបអ្វី គេសម្លាប់វា ។ — بِأَيِّ ذَنْبٍ قُتِلَتْ ٩

១០ ហើយពេលណា បញ្ជី ទាំងអស់ គេ
បានលាតត្រដាង ។

وَإِذَا الصُّحُفُ نُشِرَتْ ١٠

១១ ហើយពេលណាមេឃគេធ្វើអោយ
របើកធ្លាក់ធ្លាយឡើង ។

وَإِذَا السَّمَاءُ كُشِطَتْ ١١

១២. ហើយពេលណាឋាននរក គេបាន
បញ្ឆេះឡើង ។

وَإِذَا الْجَحِيمُ سُعِّرَتْ ١٢

១៣ ហើយពេលណាឋានសួគ៌ គេបាននាំមក

وَإِذَا الْجَنَّةُ أُزْلِفَتْ ١٣

១៤ នោះបានជា បានដឹងហើយនូវ ទាំងអស់
វិញ្ញាណខ័ន្ធ អ្វីៗដែលវាបានប្រព្រឹត្តមក
ហើយនោះ ។

عَلِمَتْ نَفْسٌ مَا أَحْضَرَتْ ١٤

១៥. ពិតប្រាកដ អញបានស្បថនឹងផ្កាយ អាល់
ខុនណាស(الخنس) ដែលមានពន្លឺនៅពេល
ថ្ងៃ) ។

فَلَا أُقْسِمُ بِالْخُنَّسِ ١٥

១៦. ដែលដើរវិញ ហើយនៀតនឹងផ្កាយ
អាល់គុនណាស(الكنس) ដែលមានពន្លឺនៅ
ពេលយប់)

الْجَوَارِ الْكُنَّسِ ١٦

១៧. ហើយបានស្បថនឹងយប់ ពេលណាបាន
ដកអស់ពន្លឺនៃរបស់វា ។

وَاللَّيْلِ إِذَا عَسْعَسَ ١٧

١٨ وَالصُّبْحِ إِذَا تَنَفَّسَ

១៨. ហើយបានស្បថនឹងពេលទៀបភ្លឺ
ពេលណាវាបានបញ្ចេញរស្មី

١٩ إِنَّهُ لَقَوْلُ رَسُولٍ كَرِيمٍ

១៩ ពិតប្រាកដ អាល់គួរអាន (القرآن) គឺជាពាក្យសំដី របស់អ្នកនាំសារដ៏ថ្លៃថ្នូរ

٢٠ ذِي قُوَّةٍ عِندَ ذِي الْعَرْشِ مَكِينٍ

២០ អ្នកដែលមានឫទ្ធានុភាព ដោយមានកន្លែងដ៏ខ្ពង់ខ្ពស់ នៅជិតអ្នកដែលគ្រប់គ្រងអារ៉ស (العرش) នឹងរឹងប៉ឹង។

٢١ مُطَاعٍ ثَمَّ أَمِينٍ

២១. អ្នកដែលគេស្តាប់បង្គាប់តាម នៅទីនោះ ហើយអ្នកដែលគេមានសេចក្តីទុកចិត្ត។

٢٢ وَمَا صَاحِبُكُم بِمَجْنُونٍ

២២. ហើយសំឡាញ់របស់អ្នកទាំងឡាយ (មូហាំម៉ាត់) មិនមែនជាមនុស្សឆ្កួតលីលាទេ។

٢٣ وَلَقَدْ رَآهُ بِالْأُفُقِ الْمُبِينِ

២៣. ហើយពិតប្រាកដ (មូហាំម៉ាត់) បានឃើញវា [ជីបព្រីល (جبريل)] នៅឯមុខមាត់ (الافق) (ជើងមេឃ) យ៉ាងច្បាស់លាស់។

٢٤ وَمَا هُوَ عَلَى الْغَيْبِ بِضَنِينٍ

២៤ ហើយគាត់ (មូហាំម៉ាត់) មិនកំណាញ់ការ ការប្រាប់ពីអ្វីៗ (ដែលគាត់បានឃើញ)។

٢٥ وَمَا هُوَ بِقَوْلِ شَيْطَانٍ رَّجِيمٍ

២៥: ហើយគាត់នេះ អាល់គួរអាន (القرآن) នោះ ជាពាក្យសំដី របស់ព្រាយបិសាចដែលត្រូវគេបណ្តេញចោល

២៦ តើបានជា ដែលណាទៅ អ្នកឯងទាំងឡាយ
គ្នា នឹងផ្ទៀងដើរឆ្ពោះទៅ ។ — ٢٦ فَأَيْنَ تَذْهَبُونَ

២៧. គម្ពីរនេះ (អាល់គួរអាន) លើកលែងតែ
ជាការរំលឹក ទៅលើពិភពលោក ។ — ٢٧ إِنْ هُوَ إِلَّا ذِكْرٌ لِّلْعَالَمِينَ

២៨. សំរាប់អ្នកណា ហើយដែលប្រាថ្នាចង់ — ٢٨ لِمَن شَاءَ مِنكُمْ أَن يَسْتَقِيمَ
ហើយពួកឯងទាំងអស់គ្នានោះ ទៅលើផ្លូវដែល
ត្រឹមត្រូវ ។

២៩. ហើយគ្មានបានផ្តួចគោលបំណងអ្នកឯងទាំង — ٢٩ وَمَا تَشَاءُونَ إِلَّا أَن
អស់គ្នានោះទេ លើកលែងតែ អុលឡោះ ជា — يَشَاءَ اللَّهُ رَبُّ الْعَالَمِينَ
ម្ចាស់ពិភពលោក មានប្រាថ្នា យល់ព្រម ។

ពិតតកថាវិគ ខគម្ពីរនេះ បានបញ្ជាក់ អំពីហេតុការណ៍ដែលកើតឡើង នៅថ្ងៃនោះកាល ([illegible]) ។ ដោយសារការពិតគម្ពីរអាន: រំការផ្តល់មកអំពី អុលឡោះ ([illegible]) ហើយនឹងអំពីអង្គការរូតរបស់អុលឡោះដ៏ មួយផ្លាំង [illegible] ។

ទ្រង់បានធ្វើមុខជូរ عبس

សូរ៉ោះវគ្គនេះគេបានបញ្ចុះនៅម៉ាក្កាត់ ដែលមាន ៤២ ឃ្លា ។
គេបានបញ្ចុះវគ្គនេះ ក្រោយពីពេលដែលគេបានបញ្ចុះវគ្គ النجم
ឈ្មោះ عبس មានន័យថា បានធ្វើមុខជូរ
គេបានយកពាក្យសំដី عبس ដែលមាននៅក្នុងឃ្លាទីមួយធ្វើជា
ឈ្មោះវគ្គនេះ ។

ហេតុនាំឲ្យកើតព្រឹត្តិការណ៍ដែលនាំមក នាពេលនោះឯង រ៉ស៊ូលុល្លោះ សម្ដេចនូររបស់អល់ឡោះ បានអង្គុយពិភាក្សាជាមួយនឹងអ្នកមុខក្រុមការ៉ាអិតគូរ៉ៃស ដោយសារៈ(ហេតុ)សង្ឃឹមថា មុខអ្នកទាំងអស់នឹងចូលសាសនា ។ ក្នុងពេលនោះឯង បានដល់មកហើយ អ៊ិបនូម៉ាក់ទូម (ابن مكتوم) គាប់គួរសិស្សម្នាក់របស់សម្ដេចនូររបស់អល់ឡោះ ដែលពិការភ្នែក ហើយគាត់មានចិត្តសង្ឃឹមថា សម្ដេចនូររបស់អល់ឡោះ (رسول الله) ពុកមាត់ស្ដាប់ឃ្លាខ្លះៗនៃព្រះគម្ពីរកាល់ឃួរអាន នៅពេលនោះគាត់ ដែលរ៉ស៊ូលុល្លោះខ្វល់បានបញ្ចុះមកនោះ ។ តែថាសម្ដេចនូររបស់អល់ឡោះ (رسول الله) រ៉ស៊ូលុល្លោះមិនសូវពេញចិត្តសោះ លោកបានធ្វើមុខជូរ ហើយបែរព្រះភក្ត្រចេញពី អ៊ិបនូម៉ាក់ទូម (ابن مكتوم) ដែលជាអ្នកពិការនោះ ។

បន្ទាប់មកហើយ អល់ឡោះបានបញ្ចុះវគ្គនេះ (عبس) ដើម្បីនឹងព្រមាន ទៅលើកាយវិការរបស់សម្ដេចនូររបស់អល់ឡោះ (رسول الله) ទៅលើជនពិការ អ៊ិបនូម៉ាក់ទូម (ابن مكتوم) នោះឯង ។

គោលការណ៍សំខាន់ៗក្នុងន័យរបស់វគ្គ

១. ការជំនឿ ÷

ភស្តុតាងដែលបង្ហាញថា អល់ឡោះជាម្ចាស់ តែមួយគត់ នៅពេលដែលមនុស្សលោក ស្លាប់ទៅក្នុងសភាពការណ៍ណាមួយក៏ដោយ ។

២) ចលនាបដិវត្តន៍ក្នុងសាសនា ត្រូវតែមានដំរិះខ្សែស្ទៀតពេក
ចំពោះអ្នកដែលលើសលប់ បញ្ចូលមកក្នុងលក្ខណៈនៃសាសនា ។

អល់ឡោះម្ចាស់ទ្រង់បានបង្គាប់ចំពោះមនុស្សលោក ដែលឃ្លាតរក
ដើម្បីសំណាងគុណ ទៅចំពោះការបោកបញ្ឆោតនៃក្តីស្រលាញ់លោកិយរបស់ទ្រង់ ។

عبس

វាបានធ្វើមុខជូរ

ដោយព្រះនាមអល់ឡោះ ម្ចាស់ទ្រង់មហា
ករុណាណាស់ទៀត ទ្រង់មហាមេត្តាប្រណី ។

بِسْمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ

១. វាធ្វើមុខជូរ ហើយវាបានបែរមុខចេញ ។

عَبَسَ وَتَوَلّٰى ١

២ ដោយមនុស្សខ្វាក់ម្នាក់បានមកដល់ហើយ
ចំពោះវា ។

أَنْ جَاءَهُ الْأَعْمٰى ٢

៣. ហើយតើអ្នកឯងដឹងដែរឬទេ? ប្រ
ហែលជាវាចង់សំអាតខ្លួនវា ។

وَمَا يُدْرِيْكَ لَعَلَّهُ يَزَّكّٰى ٣

៤. ឬក៏វាចង់បានការរំឭក ដោយសារ
ការរំឭកនោះនាំអោយមានដល់ប្រយោជន៍
និងសំរាប់វា ។

أَوْ يَذَّكَّرُ فَتَنْفَعَهُ الذِّكْرٰى ٤

៥. ចំពោះអ្នកណាគាត់ស្មានខ្លួនវាគ្រប់
គ្រាន់

أَمَّا مَنِ اسْتَغْنٰى ٥

៦. ទើបប្រាកដជា អ្នកឯង ទទួលគាត់ ដោយរាក់ទាក់ — ٦ فَأَنتَ لَهُ تَصَدَّىٰ

៧. ហើយគ្មានពាក់ព័ន្ធទេ លើអ្នកឯងសោះ ទៅលើអ្នកដែលមិនបើសំអាតខ្លួនរបស់គាត់ ។ — ٧ وَمَا عَلَيْكَ أَلَّا يَزَّكَّىٰ

៨. ហើយទើបប្រាកដជា អ្នកណាបានមកដល់ឯង ដោយប្រញាប់ប្រញាល់ (ដើម្បីសួររកពិសេស) — ٨ وَأَمَّا مَن جَاءَكَ يَسْعَىٰ

៩. ហើយគាត់នោះ អ្នកដែលកោតខ្លាច ។ — ٩ وَهُوَ يَخْشَىٰ

១០. ទើបប្រាកដជា ឯងគ្មានយកចិត្តទុកដាក់នឹងគាត់ទេ ។ — ١٠ فَأَنتَ عَنْهُ تَلَهَّىٰ

១១. កុំធ្វើដូចនោះអី ពិតប្រាកដណាស់ប្រយោគទាំងនេះ រវាល់គួរអាន (អាយ៉ាត់ ...) ជាមេរៀនដាស់រំឭក ។ — ١١ كَلَّا إِنَّهَا تَذْكِرَةٌ

១២ ទើបប្រាកដជា អ្នកណាដែលមានបំណងចង់ ឲ្យគាត់ យកចិត្តទុកដាក់នឹងវា (ព្រះ) ។ — ١٢ فَمَن شَاءَ ذَكَرَهُ

១៣. នៅក្នុងព្រះគម្ពីរដែលគេលើកដំកើង ។ — ١٣ فِي صُحُفٍ مُّكَرَّمَةٍ

១៤ នៅកន្លែងដ៏មហាខ្ពង់ខ្ពស់ដែលជ្រះស្អាត — ١٤ مَّرْفُوعَةٍ مُّطَهَّرَةٍ

១៥. នៅនឹងដៃនៃ (ملئكة) អ្នកសរសេររបស់ អុលឡោះ ។ | ١٥ بِأَيْدِي سَفَرَةٍ

១៦. ដ៏ល្អថ្លៃថ្នូរ ហើយប្រសើរបំផុត តាម | ١٦ كِرَامٍ بَرَرَةٍ

១៧. គេបានជេរការលាក្ខណ៍ មនុស្សលោក ហេតុមកអំពី ភាពគ្មានសេចក្ដីជឿ ចំពោះព្រះអង្គ | ١٧ قُتِلَ الْإِنْسَانُ مَا أَكْفَرَهُ

១៨. អំពីអ្វីទៅ ដែលអុលឡោះបានបង្កើតគាត់នោះ ។ | ١٨ مِنْ أَيِّ شَيْءٍ خَلَقَهُ

១៩. អំពីមួយដំណក់ទឹកកាម អុលឡោះបានបង្កើតគាត់ ហើយបានបំពេញលក្ខណៈរបស់គាត់ ។ | ١٩ مِنْ نُطْفَةٍ خَلَقَهُ فَقَدَّرَهُ

២០. បន្ទាប់មក អុលឡោះបានសម្រួលផ្លូវគាត់ ។ | ٢٠ ثُمَّ السَّبِيلَ يَسَّرَهُ

២១ បន្ទាប់មកទៀត អុលឡោះបានបញ្ចូលគាត់ទៅក្នុងមរណភាព ហើយបានបញ្ចូលគាត់ទៅក្នុងផ្នូរ ។ | ٢١ ثُمَّ أَمَاتَهُ فَأَقْبَرَهُ

២២. បន្ទាប់មកទៀត ពេលណាហើយទ្រង់ចង់ ព្រះអង្គទ្រង់បញ្ចេញហើយគាត់ (មនុស្សអំពីផ្នូរ) ។ | ٢٢ ثُمَّ إِذَا شَاءَ أَنْشَرَهُ

២៣ ក៏ពុំដូច្នោះអី កាលណាហ៊ានគោរពសម្រេច- | ٢٣ كَلَّا لَمَّا يَقْضِ مَا أَمَرَهُ

កិច្ចប្រតិបត្តិ នូវអ្វីៗដែលរសូលឲ្យធ្វើ ទ្រង់
ឡើយ ។

២៤. ដូច្នេះមនុស្សលោកសម្លឹងគិតគូរ ទៅ ចំពោះចំណីអាហាររបស់គេ ។ فَلْيَنظُرِ الْإِنسَانُ إِلَىٰ طَعَامِهِ 24

២៥. ពិតប្រាកដ យើងបានបញ្ចោះហើយ ទឹកភ្លៀង បញ្ចុះយ៉ាងច្រើនពាសពេញ أَنَّا صَبَبْنَا الْمَاءَ صَبًّا 25

២៦. បន្ទាប់មក យើងបានបំបែកដី បំបែក ខ្លះៗ ។ ثُمَّ شَقَقْنَا الْأَرْضَ شَقًّا 26

២៧. ដូច្នេះយើងបានបណ្ដុះហើយ បណ្ដាគ្រាប់ធញ្ញជាតិ ទៅក្នុងវា ។ فَأَنبَتْنَا فِيهَا حَبًّا 27

២៨. ហើយដើមទំពាំងបាយជូរ ហើយនិងបន្លែ នានា ។ وَعِنَبًا وَقَضْبًا 28

២៩. ហើយដើមអូលីវ ហើយនិងដូង (ឥន្ទផ្លាំ) ។ وَزَيْتُونًا وَنَخْلًا 29

៣០. ហើយចំការដែលមានដំណាំដុះក្រាស់ និង ឡើងខ្ពស់ ។ وَحَدَائِقَ غُلْبًا 30

៣១. ហើយផ្លែឈើនានា ហើយនិងកល ស្មៅ ។ وَفَاكِهَةً وَأَبًّا 31

៣២. ដើម្បីសោយបាន ជាប្រយោជន៍សុខស្រួល សំរាប់អ្នកទាំងអស់គ្នា ហើយសំរាប់សត្វពាហនៈរបស់អ្នកទាំងអស់គ្នាណា ។ — مَتَاعًا لَّكُمْ وَلِأَنْعَامِكُمْ ٣٢

៣៣. ដើម្បីពេលណាបានដល់មកហើយសម្លេងខ្លាំងក្លា ។ — فَإِذَا جَاءَتِ الصَّاخَّةُ ٣٣

៣៤. នៅថ្ងៃនោះ មនុស្សលោករត់ចោលបងប្អូនរបស់វា — يَوْمَ يَفِرُّ الْمَرْءُ مِنْ أَخِيهِ ٣٤

៣៥ ហើយរត់ចោលមាតានិងបិតារបស់វា ។ — وَأُمِّهِ وَأَبِيهِ ٣٥

៣៦. ហើយនិងរត់ចោលភរិយា និងបុត្រធីតារបស់វា ។ — وَصَاحِبَتِهِ وَبَنِيهِ ٣٦

៣៧. ពីព្រោះ គ្រប់ៗម្នាក់ៗ ពួកគេទាំងអស់នោះ នៅថ្ងៃនោះរឹងមានកិច្ចការរវល់រៀងៗខ្លួន — لِكُلِّ امْرِئٍ مِّنْهُمْ يَوْمَئِذٍ شَأْنٌ يُغْنِيهِ ٣٧

៣៨. មុខមនុស្សខ្លះ នៅថ្ងៃនោះមានពន្លឺភ្លឺ — وُجُوهٌ يَوْمَئِذٍ مُّسْفِرَةٌ ٣٨

៣៩. សើចក្អាកក្អាយ ពោរពេញទៅដោយក្តីសប្បាយរីករាយនិងត្រេកអរ ។ — ضَاحِكَةٌ مُّسْتَبْشِرَةٌ ٣٩

៤០ ហើយទៀតមុខមនុស្សខ្លះ នៅថ្ងៃនោះ ប្រឡាក់ដោយធូលី ។ — وَوُجُوهٌ يَوْمَئِذٍ عَلَيْهَا غَبَرَةٌ ٤٠

៤១. ហើយគ្របដណ្ដប់ទៅដោយភាពងងឹត ។ تَرْهَقُهَا قَتَرَةٌ ٤١

៤២ អ្នកទាំងអស់នោះហើយ គឺជាពួក អ្នក គ្មានជំនឿ ដែលទាំងបានប្រព្រឹត្តអំពើ អាក្រក់ល្មើសជាទីបំផុត أُولَـٰئِكَ هُمُ الْكَفَرَةُ الْفَجَرَةُ ٤٢

ឋិតកថាវត្ត វគ្គនេះគេបានដង្កក្រុងយកមកបញ្ជាក់ នូវការទំនួល
របស់រសូលុលឡោះ ចំពោះអ្នកពិការភ្នែករបស់រសូលុលឡោះ (رسول الله)
ដែលបានបង្រៀនអ្នកមុខអ្នកការ ជាតិ គូរ៉ស ។ ក្នុងពេលដែលប្រទះរសូលុល-
-ឡោះ នេះជា មុខការអ្នកទាំងនោះ ចូលមកគាល់លោកសុំសួរ ចំនេះដឹងពី
ក្រុងការបង្រៀនជាតិ គូរ៉សនេះ ការងារការបង្រៀន រឿងសង្គមគុណ (ស្រីយ៉ា) ដែលពិត
ពិភពនេះ ទៅទៀត ។
គេបានបញ្ជាក់យ៉ាងច្បាស់លាស់ នូវជំនឿជឿរបស់ជាតិ គូរ៉សនោះ ។
គឺប្រព្រឹត្ត គួរអាន (ចាំ) សាស្នាវិញ្ញាណដោយទាំងបាន ។
ដែលលក្ខណៈរបស់មនុស្សលោក គ្មានដឹងពិតជិតការជំនួសអំណាចអគ្គហេតុ
ចំពោះរសូលុលឡោះ ទៅពីការប្រកាសការពោតដែល គឺសុទ្ធតែស្មោះស្ម័គ្ររបស់ទ្រង់
ឡើយ ។

មដ្ឃរាជ النازعات

គម្ពីរវគ្គ វគ្គនេះ គេបានបញ្ចុះនៅម៉ាក្កាស់ ដែលមាន ៤៦ ឃ្លា ។
គេបញ្ចុះវគ្គនេះក្រោយពីពេលដែលគេបានបញ្ចុះវគ្គ النبا
ឈ្មោះ النازعات មានន័យថា មដ្ឃរាជ (អ្នកដែលដកជីវិត) ។
គេយកពាក្យតាមពាក្យសព្ទដើមថា النازعات ដែលមាននៅក្នុងបន្ទាត់ដំបូង ឃ្លាទី១ នៃវគ្គនេះ ។
ទៀតគេហៅឈ្មោះថា الساهرة ដែលគេបានយកពាក្យនេះមកពីឃ្លាទី ១៤ នៃវគ្គនេះ ។

គោលការណ៍សំខាន់ៗក្នុងន័យរបស់វគ្គ

១- ជំនឿ: អល់ឡោះបាននាំថា គង់តែមកដល់ថ្ងៃវិនាសកាលពិត ។
ហើយរាល់ការប្រកែករបស់បណ្ដាអ្នកដែលបញ្ចូលសព្វៗទៅ
លាយឡំក្នុងប្រព្រឹត្តរបស់អល់ឡោះ គឺអ្នកមុស្រិក (مشركين) ។
-ទើបមនុស្សលោកនោះ គេដឹងថែកកោតខ្លាចឬមិនអាចបំភ្លេចនោះ ។
- ទៀតមនុស្សលោកនឹងលត់ទានទីបំផុត ហើយក៏គោរពការណ៍ដែលកើតមាន
ឡើងនៃវេលាកាល ថ្ងៃវិនាសកាល (قيامة) ។
២/ និទានរឿង គេនិទានរឿងណាពីមូសា: (ណាពី) ជួបជាមួយ -
ហ្វៀរ៉ូន (فرعون)

النازعات

មដ្ឃរាជ

ដោយព្រះនាមអល់ឡោះ ម្ចាស់ដ៏មហា
ករុណា ទៀតដ៏មហាមេត្តាប្រណី ។

بِسْمِ اللهِ الرَّحْمَنِ الرَّحِيمِ

١ وَالنَّـٰزِعَـٰتِ غَرْقًا

១. (អល់ឡោះ) បានស្បថនឹង មេឡាកាត់ (ملئكة عزرائيل) ដែលដកវិញ្ញាណ ដោយ[illegible] ។

٢ وَالنَّـٰشِطَـٰتِ نَشْطًا

២. ហើយ (អល់ឡោះ) បានស្បថនឹង មេឡាកាត់ (ملئكة) ដែលដកវិញ្ញាណដោយ ទន់ភ្លន់ ។

٣ وَالسَّـٰبِحَـٰتِ سَبْحًا

៣. ទៀតសោត បានស្បថនឹង ពពួកទេវៈ (ملئكة) ដែលចុះមកពីលើមេឃ[illegible] ។

٤ فَالسَّـٰبِقَـٰتِ سَبْقًا

៤ ហើយទៀតសោត បានស្បថនឹងពពួកទេវ (ملئكة) ដែលលឿនមុនគេលឿន (ក្នុងកិច្ចការ) ។

٥ فَالْمُدَبِّرَٰتِ أَمْرًا

៥. ហើយទៀតសោត បានស្បថនឹងពពួកទេវៈ (ملئكة) ដែលរៀបចំកិច្ចការ (ក្នុងលោក) ។

٦ يَوْمَ تَرْجُفُ الرَّاجِفَةُ

៦. នៅថ្ងៃដែលគេផ្លុំស្នែង (الصور ، سنكلا) លើកទី១. បានរញ្ជួយហើយ ពិភពលោក ។

٧ تَتْبَعُهَا الرَّادِفَةُ

៧. បន្ទាប់ពីផ្លុំស្នែងលើកទី១.មក បន្តផ្លុំស្នែងលើកទី២. ។

٨ قُلُوبٌ يَوْمَئِذٍ وَاجِفَةٌ

៨. ចិត្តមនុស្ស នៅក្នុងថ្ងៃនោះ ភ័យណាស់ មហាភ្លេច

٩ أَبْصَـٰرُهَا خَـٰشِعَةٌ

៩. ឃើញនឹងភ្នែកចិត្តដោយអាប់ឱន ។

១០. ពួកទាំងអស់នោះបានពោលថា តើពួក យើងនឹងវិលមកវិញឬទេ? គេនឹងបង្វិលត្រឡប់យើង ទៅរកសភាពរស់ឡើងវិញក្រោយពេលស្លាប់។	يَقُولُونَ أَإِنَّا لَمَرْدُودُونَ فِي الْحَافِرَةِ	١٠
១១. តើខ្លួនយើងនឹងរស់ឬទេ? ពេលណាយើងនឹង ក្លាយទៅជាឆ្អឹងពុករលួយ (គេនឹងបង្កើតឡើង វិញ) ។	أَإِذَا كُنَّا عِظَامًا نَّخِرَةً	١١
១២. ពួកទាំងអស់នោះបានពោលថា បើដូច្នេះ ជាយ៉ាងដូច្នោះ ការវិលត្រឡប់នោះបាន ជាការខាតបង់ហើយ ។	قَالُوا تِلْكَ إِذًا كَرَّةٌ خَاسِرَةٌ	١٢
១៣. តែបើបានជា ពិតប្រាកដ ការវិលត្រឡប់នោះ ម្ដងយ៉ាងការរស់ឡើងវិញនោះ គឺគ្រាន់ដល់ ស្រែក ។	فَإِنَّمَا هِيَ زَجْرَةٌ وَاحِدَةٌ	١٣
១៤. តែបាន ទៅពេលនោះ ពួកទាំងអស់ នោះ ក្លាយទៅរស់លើដី (ក្រោយនឹងវិលត្រឡប់)	فَإِذَا هُم بِالسَّاهِرَةِ	١٤
១៥. តើបានមកដល់ឯងឬទេ? (មូហាំម៉ាត់) ប្រវត្តិ របស់មូសា ។	هَلْ أَتَاكَ حَدِيثُ مُوسَىٰ	١٥
១៦. ពេលណាម្ចាស់គេ បានហៅគេ នៅលើដី ទុប (ដូវ៉ា) ដ៏ត្រៃល្អ ។	إِذْ نَادَاهُ رَبُّهُ بِالْوَادِ الْمُقَدَّسِ طُوًى	١٦
១៧. ចូរឯងទៅរកស្ដេចហ្វៀរអ៊ូន ពិតប្រាកដ គេបានរំលងព្រំដែន	اذْهَبْ إِلَىٰ فِرْعَوْنَ إِنَّهُ طَغَىٰ	١٧

១៨. ហើយនិយាយថាៈ តើអ្នកឯងចង់ សំអាតខ្លួនដែរឬទេ ? | ١٨ فَقُلْ هَلْ لَكَ إِلَىٰ أَنْ تَزَكَّىٰ

១៩. ហើយខ្ញុំនឹងចង្អុលបង្ហាញអ្នកឯង ទៅ ជំពោះម្ចាស់របស់ឯង ដើម្បី អោយអ្នកឯងកោតខ្លាច ។ | ١٩ وَأَهْدِيَكَ إِلَىٰ رَبِّكَ فَتَخْشَىٰ

២០ បន្ទាប់មក មូសាបានបង្ហាញ ជំពោះ ហ្វៀរអ៊ូន នូវមហាអិទ្ធិឫទ្ធិយ៉ាងធំ ។ | ٢٠ فَأَرَاهُ الْآيَةَ الْكُبْرَىٰ

២១. ក៏ប៉ុន្តែ (ហ្វៀរអ៊ូន) បានចោទថាកុហក ហើយវាបានធ្វើទុច្ចរិត ។ | ٢١ فَكَذَّبَ وَعَصَىٰ

២២. ក្រោយមកវាបានដើរចេញ ដើម្បីប្រឹងប្រែង (ប្រឆាំងនឹងមូសា) | ٢٢ ثُمَّ أَدْبَرَ يَسْعَىٰ

២៣. ទើបវាបានប្រមូល ហើយបាន អំពាវនាវ (ក្រុមនិងពលរបស់វា) | ٢٣ فَحَشَرَ فَنَادَىٰ

២៤ ហើយវាបានពោលថា អញ ជាម្ចាស់របស់អ្នកឯងទាំងអស់គ្នា ដ៏មហា ខ្ពង់ខ្ពស់ ។ | ٢٤ فَقَالَ أَنَا رَبُّكُمُ الْأَعْلَىٰ

២៥. ដូច្នេះអល់ឡោះ បានធ្វើទារុណកម្ម វាហើយ នៅក្នុងបរលោក និង លោកីយ៍ ។ | ٢٥ فَأَخَذَهُ اللَّهُ نَكَالَ الْآخِرَةِ وَالْأُولَىٰ

២៦. ពិតប្រាកដ ក្នុងដំណើរការណ៍ ដែលដូច | إِنَّ فِي ذَٰلِكَ لَعِبْرَةً لِّمَن ٢٦
នោះ ដើម្បីជាមេរៀនដល់អ្នកណា | يَخْشَىٰ
ដែលកោតខ្លាច ។

២៧ តើអ្នកឯងទាំងអស់គ្នាពិសេសក្នុងការលំបាក | أَأَنتُمْ أَشَدُّ خَلْقًا أَمِ السَّمَاءُ ٢٧
ក្នុងការបង្កើត ឬមួយមេឃ ដែលទ្រង់ | بَنَاهَا
បានកសាងវា ហើយមកនោះ ។

២៨ ទ្រង់បានលាបនាវា (មេឃ) ហើយ | رَفَعَ سَمْكَهَا فَسَوَّاهَا ٢٨
ទ្រង់បានបំពេញនូវលក្ខណៈរបស់វា (មេឃ) ។

២៩. ហើយទ្រង់បានបង្កើតនូវពេលយប់ | وَأَغْطَشَ لَيْلَهَا وَأَخْرَجَ ضُحَاهَا ٢٩
ងងឹតក្នុងវា (មេឃ) ហើយទ្រង់បាន
បញ្ចេញពន្លឺនៅពេលថ្ងៃក្នុងវា (មេឃ) ។

៣០. ហើយផែនដី ក្រោយពីការដូចនោះ | وَالْأَرْضَ بَعْدَ ذَٰلِكَ دَحَاهَا ٣٠
មក គេបានលាតទ្រដាងវា (ផែនដី)

៣១. ទ្រង់បានបញ្ចេញពីផែនដីនោះ | أَخْرَجَ مِنْهَا مَاءَهَا وَمَرْعَاهَا ٣١
ទឹក ហើយនិងវាលដំណាំដាំដុះ ។

៣២. ហើយបណ្តាភ្នំទាំងឡាយ ទ្រង់បានតម្រឹម | وَالْجِبَالَ أَرْسَاهَا ٣٢
វាយ៉ាងនឹងនរ ។

៣៣. ដើម្បីអោយបានការស្រណុកសុខស្រួល | مَتَاعًا لَّكُمْ وَلِأَنْعَامِكُمْ ٣٣
សំរាប់អ្នកឯងទាំងអស់គ្នា ហើយនឹងបណ្តា

សត្វពាហនៈ របស់អ្នកទាំងអស់គ្នា ។

៣៤. លុះពេលណាបានមកដល់ហើយ គ្រោះថ្នាក់ មហាធ្ងន់ធ្ងរ នឹងមកដល់ ។

فَإِذَا جَاءَتِ الطَّامَّةُ الْكُبْرَىٰ ٣٤

៣៥ នៅថ្ងៃនោះ មនុស្សលោក បាននឹកឃើញ រឿងវិញ នូវអ្វីៗ ដែលគេបានប្រព្រឹត្តិខ្លួន មកហើយនោះ ។

يَوْمَ يَتَذَكَّرُ الْإِنْسَانُ مَا سَعَىٰ ٣٥

៣៦. ហើយគេបានបង្ហាញឋាននរក សំរាប់ អ្នកណាដែលបានឃើញ ។

وَبُرِّزَتِ الْجَحِيمُ لِمَنْ يَرَىٰ ٣٦

៣៧. ចំណែកអ្នកណាៗ ហើយដែល រំលោភ ផ្ដាច់ ។

فَأَمَّا مَنْ طَغَىٰ ٣٧

៣៨ ហើយគេបានបន្ទំការរស់នៅក្នុងលោកិយ ។

وَآثَرَ الْحَيَاةَ الدُّنْيَا ٣٨

៣៩. ដូចបានជា ពិតប្រាកដ ឋាននរកនោះ ជាកន្លែង សំរាប់គេ ។

فَإِنَّ الْجَحِيمَ هِيَ الْمَأْوَىٰ ٣٩

៤០ ហើយចំណែកអ្នកណាៗ ដែលបានកោត ខ្លាចអំណោះម្ចាស់គេ នឹងបានខ្លាចខ្លួន ហើយ គេបានឃាត់ ខ្លួនគេ សំរាប់ តាមតណ្ហា ។

وَأَمَّا مَنْ خَافَ مَقَامَ رَبِّهِ وَنَهَى النَّفْسَ عَنِ الْهَوَىٰ ٤٠

៤១. នោះពិតប្រាកដ ឋានសួគ៌នោះ ជា កន្លែងសំរាប់គេ ។

فَإِنَّ الْجَنَّةَ هِيَ الْمَأْوَىٰ ٤١

៤២. អ្នកទាំងអស់នោះ នឹងសួរឯង (មូហាំម៉ាត់) អំពីថ្ងៃ បរលោក ពេលណាទៅគេ នឹង បង្កើត (ក្រោកវា) ។ — يَسْـَٔلُونَكَ عَنِ السَّاعَةِ أَيَّانَ مُرْسَاهَا ٤٢

៤៣. តើឯងទៅអ្នកឯង នឹងថ្លែងបរាំពីរឿងវា (ថ្ងៃបរលោក. [illegible]) ។ — فِيمَ أَنتَ مِن ذِكْرَاهَا ٤٣

៤៤ ចំពោះម្ចាស់ឯងតែមួយ ដែលមហាជ្រាប នឹងកំណត់ពេលវា ។ — إِلَىٰ رَبِّكَ مُنتَهَاهَا ٤٤

៤៥. ពិតប្រាកដ អ្នកឯងគ្រាន់តែជាអ្នកព្រមាន ចំពោះអ្នកណាៗ ដែលកោតខ្លាចចំពោះវា (ថ្ងៃបរលោក) ។ — إِنَّمَا أَنتَ مُنذِرُ مَن يَخْشَاهَا ٤٥

៤៦. គាថ្ងៃនោះ (ថ្ងៃបរលោក) អ្នកទាំងអស់ នោះ នឹងបានឃើញហើយវា (ថ្ងៃបរលោក) នោះ ហាក់បីដូចជា អ្នកទាំងអស់នោះ គ្មានការ រស់នៅលើលោកីយលោកនេះ ក្រែលតែមួយល្ងាច ពេលល្ងាច ឬពេលព្រឹក ប៉ុណ្ណោះ ។ — كَأَنَّهُمْ يَوْمَ يَرَوْنَهَا لَمْ يَلْبَثُوا إِلَّا عَشِيَّةً أَوْ ضُحَاهَا ٤٦

បរិកថារឿង ក្រុងនេះគ្មានបញ្ជាក់អំពី សញ្ញាដ៏ របស់ស្រុកឈ្មោះ [illegible] (عاد) ដោយគ្រប់ [illegible] របស់ [illegible] ដោយប្រាកដ ថ្ងៃនេះកាល (قيامة) នោះ [illegible] ឆ្នាំ ។ [illegible] ស្រុកឈ្មោះ នឹងបង្កើត មនុស្សលោក [illegible] មួយ [illegible]

· អ្នកព្យោះនិង បណ្ដើតឡើងវិញ ដោយសារព្រះរសូល
· ហើយនិងការកម្រោមក៏ហេរ ទៅចំពោះបណ្ដាអ្នកដែល បរិភោគ
នូវការបណ្ដើតឡើងវិញ ។

· តាមព្រះគម្ពីរដែលហៅថាកុរអាន បាននិយាយមកហើយនោះ ព្រះអា
មួយអង្គ និងអ្នកដែលកាចហៅថាម៉ូស្លីម ។

វិគ្គលះ បាន បញ្ជាក់ឡើងនូវព្រឹត្តិការណ៍ដែលកើតឡើង របស់បណ្ដា
អ្នកមូស្លីម (مسلمين) នៅក្នុងលោកខាង (قيامة) ។

ថៃបណាដែរ ! តាមព្រះគម្ពីរ ហើយលោក លោក និងមហាស្មោះនៅក្នុង
លោកខាងនោះ ។

ពត៌មានដ៏សំខាន់ النبأ

កំណើតវគ្គ ៖ គេបានបញ្ចុះវគ្គនេះនៅម៉ាក្កះ ដែលមាន ៤០ ឃ្លា ។ គេបានបញ្ចុះវគ្គនេះក្រោយពីពេលដែលគេបានបញ្ចុះវគ្គ المعارج ឈ្មោះ النبأ មានន័យថា ពត៌មានដ៏សំខាន់ ។ គេយកមកធ្វើជាពាក្យសំដី النبأ ដែលមាននៅក្នុងឃ្លាទី២នៃវគ្គនេះ ។

គេហៅឈ្មោះទៀតថា يتساءلون ក៏ដែលគេយកមកធ្វើជាពាក្យសំដី يتساءلون ក៏ដែលបានមកពីឃ្លាដំបូងបង្អស់នៃវគ្គនេះ ។

គោលការណ៍សំខាន់ៗក្នុងន័យរបស់វគ្គ

ជំនឿ៖

បណ្ដាអ្នកមុសរិគីន (مشركين) ដែលបានបដិសេធនៅថ្ងៃដែលគេបានបង្កើតមនុស្សលោកឡើងវិញ ហើយមិនជឿនឹងពាក្យរបស់រ៉សូលុល្លោះ ទៅលើជំពោះភាពឫកពាររបស់អ្នកទាំងអស់នោះ ។

រ៉សូលុល្លោះ មានប្រសាសន៍ ដែលគេបានឃើញក្នុងលោកិយនេះ ជាភស្តុតាងមានថ្ងៃបង្កើតឡើងវិញ ។

ហេតុការណ៍កើតឡើងនៅថ្ងៃដែលគេបង្កើតមនុស្សលោកឡើងវិញ នៅថ្ងៃនោះឯង ។ ចំពោះបណ្ដាអ្នកដែលបានភូតភរកុហក នឹងភស្តុតាងរបស់រ៉សូលុល្លោះនោះ អ្នកទាំងនោះនឹងទទួលទារុណកម្មដ៏ធ្ងន់ធ្ងរ

រីឯបណ្ដាអ្នកដែលមានជំនឿជឿនឹងភស្តុតាងរបស់រ៉សូលុល្លោះ អ្នកទាំងនោះហើយ ប្រាកដជានឹងបានទទួលនូវបៀវត្សរ៍ជាច្រើនទៀត ។

អ្នកដែលគ្មានជំនឿ (كافر) នោះ មុខជាមានវិប្បដិសារី សុំក្លាយជាដីវិញទៀត នៅពេលថ្ងៃព្រះកាល (قيامة) នោះ ។

النبأ

ពត៌មានដ៏សំខាន់

ដោយព្រះនាមអល់ឡោះ ម្ចាស់ដ៏មហា សប្បុរសទៀតដ៏មហាមេត្តាប្រណី ។ بِسْمِ اللَّهِ الرَّحْمَٰنِ الرَّحِيمِ

១. តើពីអ្វីទៅ អ្នកទាំងអស់នោះសួរគ្នាទៅវិញទៅមក ។ ١ عَمَّ يَتَسَاءَلُونَ

២. គឺពីពត៌មានដ៏មហាសំខាន់ ។ ٢ عَنِ النَّبَإِ الْعَظِيمِ

៣. ដែលអ្នកទាំងអស់នោះខ្វែងយោបល់គ្នាលើវា (ពត៌មាន) ។ ٣ الَّذِي هُمْ فِيهِ مُخْتَلِفُونَ

៤. ចូរកុំជឿដូចនោះអី! អ្នកទាំងអស់គេនឹងដឹង ។ ٤ كَلَّا سَيَعْلَمُونَ

៥. បន្ទាប់មក ចូរកុំជឿដូចនោះអី! អ្នកទាំងអស់គេនឹងដឹងទៀត ។ ٥ ثُمَّ كَلَّا سَيَعْلَمُونَ

៦ ពុំមែនទេឬ? យើងបានបង្កើតផែនដី ឲ្យដូចកម្រាល ។ ٦ أَلَمْ نَجْعَلِ الْأَرْضَ مِهَادًا

៧. ហើយបង្កើតភ្នំទាំងឡាយ ឲ្យដូចជាស្នឹង ។ ٧ وَالْجِبَالَ أَوْتَادًا

៨. ហើយយើងបានបង្កើតអ្នកទាំងអស់គ្នាជាគូៗ ។ ٨ وَخَلَقْنَاكُمْ أَزْوَاجًا

៩. ហើយយើងបានបង្កើតការដេក របស់ពួកឯង
ទាំងអស់គ្នា ឲ្យជាការឈប់សំរាក ។

9 وَجَعَلْنَا نَوْمَكُمْ سُبَاتًا

១០. ហើយយើងបានបង្កើតពេលយប់
ឲ្យជាសំលៀកបំពាក់

10 وَجَعَلْنَا اللَّيْلَ لِبَاسًا

១១ ហើយយើងបានបង្កើតពេលថ្ងៃ
ឲ្យជាការរស់នៅ ។

11 وَجَعَلْنَا النَّهَارَ مَعَاشًا

១២ ហើយយើងបានកសាងនៅលើលើពួក
ឯងទាំងអស់គ្នា ប្រាំពីរជាន់ដែលមានភាព
រឹងមាំ ។

12 وَبَنَيْنَا فَوْقَكُمْ سَبْعًا شِدَادًا

១៣ ហើយយើងបានបង្កើត ចង្កៀងដែលមាន
ពន្លឺភ្លឺចិញ្ចែង ។

13 وَجَعَلْنَا سِرَاجًا وَهَّاجًا

១៤ ហើយយើងបានបញ្ចុះទឹកភ្លៀងពីពពក
ទឹកដ៏ច្រើន ។

14 وَأَنْزَلْنَا مِنَ الْمُعْصِرَاتِ مَاءً ثَجَّاجًا

១៥. ដើម្បីយើងនឹងបញ្ចេញនូវពីវានូវ
គ្រាប់ធញ្ញជាតិ ហើយនិងដំណាំនានា ។

15 لِنُخْرِجَ بِهِ حَبًّا وَنَبَاتًا

១៦. ហើយនិងសួនច្បារពោរពេញទៅ
ដោយរុក្ខជាតិ គ្រប់ប្រភេទយ៉ាងច្រើន ។

16 وَجَنَّاتٍ أَلْفَافًا

១៧. ពិតប្រាកដនៅថ្ងៃកាត់សេចក្តី (ថ្ងៃជំនុំជំរះ)

17 إِنَّ يَوْمَ الْفَصْلِ كَانَ مِيقَاتًا

- គឺជាថ្ងៃវិនិច្ឆ័យកំណត់ទុក ។

១៨. នៅថ្ងៃនោះ គេផ្លុំស្នែង
(سنكلا ، اَلصُّوْر) ហើយអ្នកនឹងទាំងអស់គ្នា
បានមកជាក្រុមៗ ។

يَوْمَ يُنفَخُ فِي الصُّورِ 18
فَتَأْتُونَ أَفْوَاجًا

១៩. ហើយគេបានបើកមេឃ ដើម្បីមេឃ
បានក្លាយទៅជាមាត់ទ្វារជាច្រើន ។

وَفُتِحَتِ السَّمَاءُ فَكَانَتْ 19
أَبْوَابًا

២០. ហើយគេបានបក្លាក់ឲ្យភ្នំផ្លាស់ទី
ក្លាយ ដើម្បីហើយភ្នំទាំងនោះ
សន្លាក់ដូចជាពពកបាត់ ។

وَسُيِّرَتِ الْجِبَالُ فَكَانَتْ 20
سَرَابًا

២១. តាមពិតនរក បាននរកនោះ បានហើយ
ជា កន្លែងឃ្លាំ(មើល)ចាំទុក ។

إِنَّ جَهَنَّمَ كَانَتْ مِرْصَادًا 21

២២ សំរាប់អ្នកបំពានច្បាប់ កន្លែងនោះ
ងឹងហើយ ជាកន្លែងអ្នកទាំងអស់នោះវិល-
ត្រឡប់ ។

لِلطَّاغِينَ مَآبًا 22

២៣. អ្នកទាំងអស់នោះ បានរស់នៅក្នុងវា
គ្រប់កាលជា ។

لَابِثِينَ فِيهَا أَحْقَابًا 23

២៤ អ្នកទាំងអស់នោះ ពុំបានភ្លក់រសជាតិ
ត្រជាក់ នៅក្នុងវាឡើយ ហើយគ្មាន
ភ្លក់ ភេសជ្ជៈផឹក ។

لَا يَذُوقُونَ فِيهَا بَرْدًا 24
وَلَا شَرَابًا

២៥. លើកលែងទឹកមហាសែនក្តៅ ហើយ | إِلَّا حَمِيمًا وَغَسَّاقًا ٢٥
និងខ្ទុះ ។

២៦. ជាការតបស្នងដោយសមហេតុសមផល | جَزَاءً وِفَاقًا ٢٦

២៧. ពិតប្រាកដ អ្នកទាំងអស់នោះ កាលពី | إِنَّهُمْ كَانُوا لَا يَرْجُونَ ٢٧
មុន អ្នកទាំងនោះគ្មានសង្ឃឹមថា និងមាន | حِسَابًا
ការជំនុំជំរះទេ ។

២៨. ហើយ អ្នកទាំងអស់នោះបានកុហក | وَكَذَّبُوا بِآيَاتِنَا كِذَّابًا ٢٨
នឹងអាយាត់ របស់យើង កុហកដោយ
ពិតប្រាកដ ។

២៩. ហើយគ្រប់សព្វការទាំងអស់ដែល | وَكُلَّ شَيْءٍ أَحْصَيْنَاهُ كِتَابًا ٢٩
យើងបានកត់ត្រា រាប់ចំនួនហើយនៅ
ក្នុងក្រាំងគម្ពីរ ។

៣០. ដូច្នេះ ចូរអ្នកឯងទាំងអស់គ្នា ត្រូវ | فَذُوقُوا فَلَنْ نَزِيدَكُمْ إِلَّا ٣٠
ភ្លក់ជារសជាតិ ហើយយើងនឹង | عَذَابًا
បន្ថែមដល់អ្នកឯងទាំងអស់គ្នា លើក
លែងតែ ការទារុណកម្មដ៏ខ្លាំងក្លា ។

៣១. ពិតប្រាកដ ចំពោះអ្នកដែលកោតខ្លាច | إِنَّ لِلْمُتَّقِينَ مَفَازًا ٣١
គេបានជ័យជំនះ ។

៣២ ជាសួនអារាម ហើយផ្លែទំពាំងបាយជូរ | حَدَائِقَ وَأَعْنَابًا ٣٢

៣៣ ហើយបណ្ដាស្ត្រីគេ ដែលពេញក្រមុំ
ពាវ័យ មានកាយស្មើគ្នាទាំងអស់ ។

٣٣ وَكَوَاعِبَ أَتْرَابًا

៣៤ ហើយពែងនាំឈើដែលពោរពេញ
(ដោយស្រាត្រៀងសុំដឹក)

٣٤ وَكَأْسًا دِهَاقًا

៣៥. គ្មានឮសោះទេ អ្នកទាំងអស់នោះ នៅ
ក្នុងវា (សួគ៌) ការដែលឥតប្រយោជន៍
ហើយនិងការភូតភរកុហក ។

٣٥ لَّا يَسْمَعُونَ فِيهَا لَغْوًا وَلَا كِذَّابًا

៣៦. ការតបស្នង របស់ម្ចាស់ឯងនឹងអំណោយ
ដ៏ច្រើនលើសលុប

٣٦ جَزَاءً مِّن رَّبِّكَ عَطَاءً حِسَابًا

៣៧. ម្ចាស់ដែលគ្រប់គ្រងលើមេឃនិងផែនដី
ហើយនិងអ្វីៗដែលនៅរវាងទាំង
ពីរវា ទ្រង់ដែលមហាសាការុណ៍
គ្មានសំណាងទេ អ្នកទាំងអស់នោះ ក្នុងការ
ថ្លែងបន្ទល់ ចំពោះទ្រង់ ។

٣٧ رَّبِّ السَّمَاوَاتِ وَالْأَرْضِ وَمَا بَيْنَهُمَا الرَّحْمَٰنِ لَا يَمْلِكُونَ مِنْهُ خِطَابًا

៣៨. នៅថ្ងៃដែលកំពូលទេវតាឈរត្រៀប ហើយ
និងពពួកទេវតា(ملك) ជាជួរៗ
អ្នកទាំងអស់នោះ គ្មាននិយាយស្តីទេ
លើកលែងតែ នរណាៗដែលបានអនុញ្ញាត
ហើយជាពោះវា ម្ចាស់ដ៏មហាសាការុណ៍
ទើបវា (មនុស្សលោក) បាននិយាយបាន ដោយ
ត្រឹមត្រូវ ។

٣٨ يَوْمَ يَقُومُ الرُّوحُ وَالْمَلَائِكَةُ صَفًّا لَّا يَتَكَلَّمُونَ إِلَّا مَنْ أَذِنَ لَهُ الرَّحْمَٰنُ وَقَالَ صَوَابًا

៣៩. នោះហើយគឺថ្ងៃដែលពិតប្រាកដ
ដើម្បីមានតែ នរណាៗដែលមានគោលបំណង
ចង់យកផ្លូវ ត្រឡប់ឆ្ពោះទៅ ម្ចាស់របស់
គេ ប្រាកដជាគេ បានរកឃើញកន្លែងដែលវិល
ត្រឡប់ ។

٣٩ ذَٰلِكَ الْيَوْمُ الْحَقُّ فَمَن شَاءَ
اتَّخَذَ إِلَىٰ رَبِّهِ مَآبًا

៤០ ពិតប្រាកដ យើងបានព្រមាន ហើយអ្នកទាំង
អស់គ្នា នៃ ទារុណកម្ម នោះជិតមកដល់ហើយ
នៅថ្ងៃនោះ មនុស្សលោកបានឃើញរបស់ដែល
គេបានប្រព្រឹត្ត ហើយសំដៅដៃទាំងពីរ
របស់គេ ហើយអ្នកដែលគ្មានជំនឿ
បានពោលថា ឱ ! វេទនា អញហើយ បើ
សិនជាអញ បើប្រសិនណា ការពី
មុនអញ ក្លាយទៅជាធូលី ។

٤٠ إِنَّا أَنذَرْنَاكُمْ عَذَابًا
قَرِيبًا يَوْمَ يَنظُرُ الْمَرْءُ
مَا قَدَّمَتْ يَدَاهُ وَيَقُولُ
الْكَافِرُ يَا لَيْتَنِي كُنتُ تُرَابًا

បិតកថាវិគ្គ វគ្គ (النبأ) បានបញ្ជាក់ពីបណ្ដាអ្នកមុស្ហរីគីន ដែលបាន
បដិសេធ ថាគ្មានថ្ងៃ ដែលគេបានបង្កើតមនុស្សលោកឡើងវិញ ហើយ
និងការ ... របស់កុលសម្ព័ន្ធ ... អ្នកទាំងនោះ ។

- គេដាក់ទារុណកម្ម ទៅដល់ពួក អ្នក មុស្ហរីគីន (مشركين) ។
- ហើយ គេ ផ្ដល់ សេចក្ដីសុខ ទៅពួកបណ្ដាអ្នកដែល
មានជំនឿ នៅថ្ងៃ ... (متقين) នោះ ។

ទំព័ររៀបរៀងនៃអត្ថបទនានា

សេចក្តីជូនដំណឹង

សូមជូនដំណឹងដល់ អស់លោក និងបងប្អូន ដែលជាទីគោរព និងជាទីស្នេហាទាំងឡាយ   សូមរង់ចាំអានវគ្គ ភាគ ២ ទៀត អំពីអាល់គួរ-អាន ពាក្យពេចន៍ខ្លះ និងចំណុចខ្លះដែលបានប្រែសម្រួល កាលពីមុន ក្រោយការចប់ ហើយនិង សន្ទនាផ្សេងៗទៀត តាមដែលខាងលើ ក្លាយជាលំនាំ   បន្ទាប់អំពីការប្រែសម្រួល អាល់គួរអាន តាមអាយ៉ាត់ (...) នេះ ។

អ៊ីនសាអល់ឡោះ ។

والله ولى التوفيق .

والسلام عليكم ورحمة الله وبركاته .





International Islamic Federation
of Student Organizations
P. O. BOX 8631
SALIMIAH - KUWAIT 22057